# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ២៣ ខែតុលា លេខ ១០

ព.ស. ២៤៩៤ – គ.ស. ១៩៥១

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

*ផ្នែកសាសនា* បញ្ជីរឿង *ទំព័រ*

ពុទ្ធសាសនានឹងគ្រិស្តសាសនា (សន្និសិទ
លោកវេជ្ជបណ្ឌិតមីគូត៌) (តមក)... លោករ៉ាយ-ប៊ុក .......... ៧២៣
តន្ទីអាស៊ីទ្វីប (តមក).......... លោករ៉ាយ-ប៊ុក .......... ៧២៧
សម្មាទិដ្ឋិកថា .................. ព្រះអាចារ្យ អាំ-សាមុល ..... ៧៣១

*ផ្នែកអក្សរសាស្ត្រ*

រឿងមនុស្សថ្មី.................. លោកផេង-ជ្រឹវ .......... ៧៤១
ការបណ្តុះនិស្ស័យ (តមក)........ ព្រះមហាឧត្តមវិជ្ជា ប៊ុង-ប៉ម .... ៧៥៦
រឿងសាមកុក (តមក)........... ឧកញ៉ា នូ-កន........... ៧៦៣
ព្រះរាជពង្សាវតារប្រទេសកម្ពុជា (តមក).. ឧកញ៉ា ឈឹម-ក្រសេម...... ៧៧១
រឿងអារក្សថ្លែងរឿងម្តែប្រាំ (តមក).... លោកសាង-សារ៉ាត........ ៧៧៧

*កំណត់នៃប្រវត្តិការណ៍*

ដំណើរមកកាន់ប្រទេសកម្ពុជានៃមហាបណ្ឌិត
គុណបាលបិយសេន ម៉ាល៉ាល៉ះសេកេរៈ (តចប់) ពុទ្ធសាសនបណ្ឌិត្យ......... ៧៨៧

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ១៤៥ រ.០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

## TABLE DES MATIÈRES

**PARTIE RELIGIEUSE** Pages


| | | |
|---|---|---|
| Bouddhisme et Christianisme (Conférence du Docteur A. Migot) (suite) | M. RAY-BUC | 723 |
| La Lumière de l'Asie (suite) | M. RAY-BUC | 727 |
| Sammâditthikathâ | VÉN. AM SAMOL | 731 |


**PARTIE LITTERAIRE**


| | | |
|---|---|---|
| La Légende de l'homme de pierre (contes et légendes roumains) | M. PHENG-CHRIEU | 741 |
| Education morale (suite) | Vén. PENG-PAM | 756 |
| Histoire de SAMKOK (suite) | Oknha NOU-KAN | 763 |
| Histoire du Royaume du Cambodge (suite) | Oknha CHHIM-KRASEM | 771 |
| Les vingt-cinq récits du mauvais génie (suite) | M. SANG-SAVATH | 777 |


**NOTES ET CHRONIQUES**


| | | |
|---|---|---|
| Voyage au Cambodge du Dr. G.P. Malalasekera, Président du Centre mondial des Bouddhistes de Ceylan (suite et fin) | Institut Bouddhique | 787 |


Prix d'abonnement annuel comprenant 12 numéros: 145$00

# ពុទ្ធសាសនា និង គ្រិស្តសាសនា

## សន្និសិទលោកវេជ្ជបណ្ឌិត មីគូត៍

លោក រ៉យ-ប៊ុក ក្រមការ នៅពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ប្រែពីទស្សនាវដ្តី "ហ្វ្រង់អាស៊ី" ខែមិថុនា ឆ្នាំ ១៩៥០

(តមក)

---

ជីវសត្វគ្មានជីវិតិន្ទ្រិយចំពោះខ្លួនពិតប្រាកដ ដោយយល់ថាជីវសត្វនេះកើតឡើងពីហេតុ ហើយមានហេតុផ្សេងៗទៀត ជាអ្នកបង្កើតពីមុនមកប្រកបដោយអនិច្ចតាធម៌ ។ ដូចជាព្រលឹង, បើតាមន័យខាងគ្រិស្តសាសនាថា ជាជីវសត្វស្ថិរវន្តប្រកបដោយនិច្ចតាភាព កកើតឡើងជាពិសេសសម្រាប់យើង តាំងពីបដិសន្ធិហើយស្ថិតនៅជានិច្ចដដែល ស្ថិតស្ថេរក្នុងពេលដែលជីវិតរស់នៅ ហើយក៏លះបង់យើងក្នុងពេលមរណភាពទៅកាន់ស្ថានសួគ៌ ។ យោបល់នេះ បើតាមពួកពុទ្ធសាសនិកជនថាជាការភាន់ប្រឡំដោយពិតៗ ដែលយើងហៅថាព្រលឹង, អត្តា (égo) នោះគឺបានន័យថា ធាតុប្រមូលជាសំណុំវិលចុះឡើងជានិច្ច ដែលហៅថា

---

១ ការយល់តាមព្រះពុទ្ធសាសនា អំពីធម្មជាតិនៃជីវសត្វមានអត្តនឹងព្យញ្ជនៈ ប្រហែលនឹងប្រាជ្ញាគួរជាទីគោរពដែលពណ៌នាក្នុងទតិសម័យទំនើប នៃវិជ្ជាសាស្ត្រចំពោះសមាសភាពនៃវត្ថុធាតុនិងរូបធាតុវិទ្យាខាងបរមាណូ ឲ្យប្រៀបធៀបរឿងនេះនឹងបណ្ឌិត រ៉ម — លិន្សសេន ដែលតែងសៀវភៅមួយឈ្មោះថា: ព្រះពុទ្ធសាសនានឹងវិទ្យាសាស្ត្រទំនើប ដែលបានចុះផ្សាយក្នុងទស្សនាវដ្តី ហ្វ្រង្ស.អាស៊ី, ខែមករា — កុម្ភៈ ១៩៥០ ទំព័រ ៦៥៨ ។

សញ្ញា, វេទនា, បដិមារូប, ចិន្តា ចូលចេញចាត់ៗ យើញៗ ដោយមានការចលនាទៅតាមអារម្មណ៍របស់ចិត្តនឹងមនោសញ្ចេតនា ហើយក្លាយទៅជាវត្ថុមួយថ្មី ដែលប្រមូលទៅហៅថានាមធម៌ (personne Psychique) ។ ចំពោះការផ្លាស់ប្តូរនូវធាតុជានិច្ច ជាបញ្ហាយ៉ាងជ្រាលជ្រៅ លំបាកនឹងយល់នឹងដោះស្រាយណាស់ គ្មានវត្ថុអ្វីមានសភាពពិតសោះឡើយ មានតែស្មារតីទឹងការបន្តនូវធាតុប្រែប្រួលពីវត្ថុចាស់ទៅជាវត្ថុថ្មីផ្សេង ដែលនាំឲ្យយល់ថា មានអត្តាមួយនៅស្ថិតស្ថេរជាប់ជានិច្ច ដូចជាទឹកជ្រោះដែលហូរចុះពីលើខ្នងភ្នំ ជាទឹកនឹង មានលក្ខណៈស្ថិតវន្ត ដោយស្មានថា បើតាមពិនិត្យចំពោះសភាពបន្តនៃរូបធាតុ ។

លទ្ធិទស្សនវិជ្ជានាំឲ្យបានផលខាងសីលធម៌ដ៏សំខាន់ហើយ, បើយកលទ្ធិនេះទៅអនុវត្តន៍ ធ្វើឲ្យមនុស្សយើងឲ្យអាចដកលើងនូវទំរង់នៃអត្តទត្តភាព (ègoisime) អំពីហទយវត្ថុពីមនោធម៌បាន ។ គេនឹងពោលពាក្យថា: "ខ្ញុំ" ថា "អាត្មា" ឯណាកើត បើ "អត្តា" នោះមិនមាន, បើ "អត្តា" នោះជាអូរប្រឡាយមួយ ក្នុងចំណោមប្រឡាយទាំងអស់មានច្រើនជាអនេកប្បការ ដែលរួបរួមទៅហៅថា ទន្លេនៃជីវភាពក្នុងប្រកាន់ឡើ? ។ ចំពោះគ្រិស្តសាសនិកជន, បើតាមន័យផ្ទុយវិញថា យើងមានព្រលឹងដែលព្រះអាទិទេព បានបង្កើតមកជាពិសេស ស្ថិតទៅក្នុងខ្លួនយើងម្នាក់ៗ ទាំងអស់គ្នា យើងមានជាតក់សនាចំពោះខ្លួនដែលនៅក្រោម

បង្គាប់បញ្ជារបស់ព្រះអាទិទេព ជានាយកពិសេសត្រួតត្រាសម្រេចជាអហំការពីលើ ។ ចំពោះមតិនេះ ដូចជាមានវត្ថុអ្វីមួយមករាំងរាធ្វើឲ្យឃ្លៀតឃ្លាតពីវត្ថុដទៃទៀត គឺជាប្រភពនៃអត្តទត្តភាព, ជាបុព្វហេតុអាចធ្វើឲ្យ "អត្តារបស់យើងឈ្មោះទាស់ទែងនឹងអត្តាបងប្អូនញាតិមិត្តរបស់យើង" ។

ខ្ញុំដឹងថាមានសិក្ខាបទរបស់អាទិទេពថា: "ចូរអ្នកស្រឡាញ់ទៅវិញ-មក" ។ ចុះហេតុម្តេចក៏យើងត្រូវស្រឡាញ់គ្នា បើយើងជាជីវសត្វទាំងអស់មានសភាពផ្សេងៗ គ្នា ហើយមានជោគវាសនានៅក្រោមបញ្ជានៃអាទិទេពទេ? ។ ដើម្បីនឹងតស៊ូនូវអត្តទត្តភាព ដែលស្ថិតនៅជាធម្មតា, ត្រូវតែលះបង់គំនិតចំពោះ "អត្តា" ដែលផុះពីកំណើតហើយត្រូវយើងកុំភ្លេចថាខ្លួនយើងជាកូនអាទិទេព មានសែស្រឡាយទាក់ទងទៅក្នុងអាទិទេព ។ តាមលទ្ធិពុទ្ធសាសនា, ធម៌ "អនត្តា" មានបំណងចង់តស៊ូដោយចំពោះ ដើម្បីនឹងដកគាស់រំលើងនូវបុព្វហេតុនៃអត្ត-ទត្តភាពឲ្យរលីងចេញពីសន្តានចិត្ត, យើងមិនមែនគ្រាន់តែជាបងប្អូនសាច់សាលោហិតជាមួយគ្នាប៉ុណ្ណោះទេ, យើងមានសភាពខ្ពង់ខ្ពស់ជាងនេះទៀត គឺយើងនឹងសត្វដែលមានជីវិតរស់នៅទាំងអស់ មានសភាពតែមួយដូចគ្នា ។ គេអាចយល់បានថា ការដែលយល់ផ្សេងអំពីមតិនៃទស្សនវិជ្ជាចំពោះ ' អត្តា " ជាកិច្ចសារវន្ត (essentiel) ដែលជាហេតុឲ្យមានយោបល់ខុសគ្នាខាងច្បាប់សីលធម៌ ដែលយើងបានអធិប្បាយពីមុន

មក ៗ លទ្ធផលខាងបច្ចិមប្រទេស, តាមគោលការណ៍, សិក្ខាបទ ត្រង់ព្រហ្មវិហារត្រឡប់ទៅជាវិសាមញ្ញភាព (Anachronisme) អត្តទត្តភាពនឹងការសង្គ្រាមនៃជីវភាព ទៅជាមានបទបញ្ញត្តិតឹងរឹងពន់ពេកចំពោះបុគ្គលនឹងប្រជាពស្ត្រ ដែលគេទុកជាសភាពផុយនឹងលទ្ធិពុទ្ធសាសនាជាសាសនាសុទ្ធជាមជ្ឈិមាបដិបទា ដែលយើងនឹងពណ៌នាទៅខាងក្រោយ ៗ

ខ្ញុំខំព្យាយាមបង្ហាញអ្នក តើព្រះពុទ្ធសាសនាដោយពិតយ៉ាងណាខ្លះ? ខ្ញុំមិនអាចនឹងពណ៌នាឲ្យបានសព្វគ្រប់ អំពីព្រះពុទ្ធសាសនាដែលពួកពុទ្ធសាសនិកជនធ្លាប់និយមកាន់នោះឡើយ ៗ ពិតមែនតែពួកបុតា-ជាតិ, បើពិនិត្យឲ្យច្បាស់លាស់តាមន័យធម្មតា ឃើញថាជាអ្នកពេញចិត្តខាងសាសនាជាងពួកបច្ចិមជាតិ តែអ្នកដែលយល់នូវសាសនា ដែលខ្លួនប្រតិបត្តិតាមសភាពដ៏ឧត្តមកម្រនឹងមាន, ហើយពួកឧបាសកនឹងឧបាសិកាតែងពេញចិត្តខាងការធ្វើបុណ្យកុសលតាមទំនៀមទម្លាប់ ដែលមានសភាពងាយស្រួលជាការត្រាប់ទៅតាមផ្លូវកត្តារ ដែលមានចង្ហក ច្រើនខាងធម៌សមាធិកម្មដ្ឋាន ៗ នាងក្សេត្រការិនី (Cultivatrice) ខ្មែរដែលអុជធូបបូជាព្រះពុទ្ធរូប គឺជាភាតរជនិកា (sœur) នៃនាងក្សេត្រ-ការិនីនៅភូមិភាគប្រឹតាញដែលអុជទៀនបូជារូបសាំង អង់ត្វានដឺប៉ាឌូ (Saint. Antoine de Padoue) តែពួកឫស្សីប្រទេសទីបេត៍ដែលស្ថិតនៅក្នុងព្រៃហេមាល័យជាភាតរជន (Frère) ចំពោះមនោធម៌នៃគ្រិស្តសាសនិក-ជនដែលស្ថិតក្នុងកុដិ នៅវិហារសារទី ៗ (មានត)

# ពន្លឺអាស៊ីទ្វីប

## វគ្គទី ៧

**La Lumière de l'Asie**

លោកស៊ើរ-អេតវិនអារណូលត៍ តែង

លោកវ៉ាយ-ប៊ុក ក្រុមការ ប្រែរៀបរៀង

(តទៅ)

---

បន្ទាប់មកពួកតាណ៌ដនោះក្រាបទូលព្រះអង្គទៅទៀតថា: រួចព្រះបរមគ្រូជាម្ចាស់ទ្រង់ធ្ងន់កាត់ក្ដី ដើម្បីនឹងស្ដេចទៅកាន់ទីក្រុងពេណារេស (ពាពណសី) ទៅប្រោសបញ្ចវគ្គិយពន្យល់អំពីរបៀបធ្វើជីវិតនឹងសេចក្ដីស្លាប់ឲ្យសាបសូន្យ ហើយមនុស្សទាំងអស់ត្រូវទទួលជោគវាសនា ចំពោះអតីតកម្មកភាពរបស់ខ្លួន, គ្មាននរកអ្វីក្រៅពីនរកដែលខ្លួនធ្វើ, មិនមានស្ថានសួគ៌ឯណាខ្ពស់ហួសប្រមាណ អំពីបុគ្គលដែលគ្មានប្រព្រឹត្តបាបអកុសល ។ ក្នុងពេលនោះគឺថ្ងៃ ១៥ ខែវ័យស្យា[១] ពេលរសៀល ហើយយប់នោះជាថ្ងៃពេញបុណ៌មី ។ ក្នុងចំណោមពួកឫស្សី, ភិក្ខុកោណ្ឌញ្ញបានត្រាស់ដឹងនូវចតុរារិយសច្ច ព្រមទាំងឃើញធម៌មុនគេ, រួចតមកភទ្រយ: (ភទ្ទិយ:), អស្វជិ (អស្សជិ), ពសវ: (វប្ប:) មហានាម បានសម្រេច ៗ នៅក្នុងឧទ្យានប្រែស (ប្រហែលជាព្រៃឫសីបតន:?) ព្រះអង្គម្ចាស់យស (យសកុលបុត្រ) ទ្រង់បានគង់ព្រះសណ្ដាប់ធម៌ទេសនានៃព្រះបរមគ្រូ ព្រមទាំងបរិវារ ៥៤ នាក់,

---

១ ខែនេះត្រូវនឹងចុងខែឧសភានឹងដើមខែមិថុនា ។

ថ្វាយបង្គំព្រះអង្គហើយក៏សម្រេចដើរតាមក្រោយព្រះអង្គ; ព្រោះសទ្ធាភាពនិងវិទ្យាសាស្ត្រនៃសម័យថ្មី បានបើកដោយសេរីចំពោះមនុស្សលោក ហើយកើតមានឡើងនៅក្នុងហទយវត្តនៃបុគ្គលដែលបានស្តាប់នូវពុទ្ធោវាទ ដូចជាបុប្ផានិងរុក្ខជាតិព័ណ៌ខៀវស្រងាត់ដុះពាសពេញកាលណាទឹកហូរចូលទៅក្នុងវាលខ្សាច់ ។

ពាណិជនោះបានក្រាបទូលព្រះនាងតទៅទៀតថា: ពួកសាវកទាំង ៦០ អង្គ, ក្រោយដែលបានសម្រេចមគ្គផល ព្រះសម្មាសម្ពុទ្ធបានបាត់ឲ្យទៅផ្សាយព្រះពុទ្ធសាសនា ពន្យល់ផ្លូវដែលទៅកាន់បរមសុខ ។ ចំណែកខាងព្រះអង្គវិញ ទ្រង់បានចាកចេញពីឧទ្យាននៃសត្វប្រើសនិងព្រៃឥសីបតនៈ ដើម្បីនឹងទ្រង់យាងទៅកាន់ខាងត្បូងយស្ហតិ (Yashti) និងព្រះរាជអាណាចក្រព្រះបាទពិម្ពិសារ ទ្រង់បានទេសនាជាច្រើនថ្ងៃទៅទីនោះ ។ ព្រះបាទពិម្ពិសារនិងប្រជារាស្ត្រក៏បានទទួលនូវត្រ័យសរណគមន៍, បានសិក្សារៀនសូត្រនូវច្បាប់ព្រហ្មវិហារនិងវិធាននៃជីវភាព ព្រមទាំងថ្វាយចំពោះទៅព្រះបរមគ្រូជាម្ចាស់ (ដោយទ្រង់បានបាក់ព្រះសុគន្ធរសក្នុងព្រះហស្តនៃព្រះសម្ពុទ្ធ)(១) នូវឧទ្យាននៃដើមឫស្សីឈ្មោះវេឡុវ័នដែលមានស្ទឹងគង្គា គុហា និងព្រៃរបោះ, ហើយព្រះមហាក្សត្របានតំកល់សិលាមួយដុំបារីកថា: "ហេតុផលនៃជីវភាព, ព្រះ

---

១ សភាពទេយ្យទានតាមច្បាប់បុរាណហិណ្ឌូ ។

តថាគត[១] បានទេសនាទូន្មានយើង ហើយដោយច្បាស់លាស់, ធម៌អ្វីដែលធ្វើសត្វឲ្យចាកចេញពីសេចក្ដីទុក្ខនៃជីវភាព, ព្រះបរមគ្រូបានព្រះរាជទានទុកទេហើយ" ។

ពាណិជទាំង ២ នាក់ពោលតទៅទៀតថា: នៅក្នុងឧទ្យាននេះមានមហាសន្និបាតមួយ ដែលព្រះបរមគ្រូទ្រង់បានទេសនាអំពីគតិបណ្ឌិត, លទ្ធិផ្សេងៗ ធ្វើឲ្យចិត្តអ្នកដែលស្ដាប់មានសភាពជ្រះថ្លាពន់ពេក ទាល់តែមានមនុស្ស ៩០០ នាក់ បានឧបសម្បទាជាភិក្ខុដូចព្រះបរមគ្រូ ហើយនាំគ្នាផ្សាយក្បួនច្បាប់ធម៌វិន័យរបស់ព្រះអង្គ ហើយទ្រង់បានបញ្ចប់ព្រះឱវាទថា: "បាននាំឲ្យបំរើនបំណុលដែលត្រូវតែសង, បុណ្យនាំមនុស្សឲ្យចេញចាកផុតពីបំណុលដោយសងបំណុលជ្រះស្រឡះ កុំធ្វើបាប, ឲ្យប្រព្រឹត្តបុណ្យ, រក្សាចិត្តឲ្យផូរផង់ៈ នេះជាផ្លូវវិសេស" ។

ដល់ពាណិជនោះពោលចប់ហើយ, ព្រះនាងទ្រង់បានចែកទេយ្យទាន ទាំងមានព្រះឧស្សព៍ពេះពីសាជាឯរតនៈទៅទៀតទៅកាន់ពាណិជ ។ ព្រះនាងទ្រង់សួរទៅពួកពាណិជថា: "ចុះព្រះសាស្ដាទ្រង់យាងមកតាមផ្លូវណា, លោកតា? ។ ពួកពាណិជក្រាបទូលព្រះនាងថា: ព្រះអង្គទ្រង់ស្ថិតនៅក្នុងទីមួយចម្ងាយពីកំពែងព្រះរាជធានី ៦០ យោជន៍ ហើយទ្រង់រៀបយាងទៅកាន់ក្រុងរាជគ្រឹះ ដែនមានផ្លូវមួយបែកទៅទីក្រុង

១ អ្នកដែលធ្វើតាមគ្នា គឺជានាមនៃព្រះសិទ្ធត្ថ ជាព្រះអង្គទ្រង់បានត្រាប់តាមផ្លូវធ្វើបញ្ញានៃព្រះពុទ្ធពីបុរាណ ។

សោណៈនឹងគិរីជាច្រើន ៗ គោទូលព្រះបង្គំទាំងអស់គ្នាបានធ្វើដំណើរមកពីទីនោះប្រាំបីកុស្សក្នុង ១ ថ្ងៃ បានមកដល់ទីក្រុងក្នុងរវាង ១ ខែ ” ។

ព្រះមហាក្សត្រទ្រង់បានជ្រាបដំណឹងនេះ បានចាត់រាជអាមាត្យក្នុងព្រះបរមរាជវាំងដ៏ះសេះ, រាជបេសកជន ៩ នាក់នឹងអគ្គរាជទូតម្នាក់ៗ បានទទួលព្រះរាជឱង្ការនូវព្រះបន្ទូលស្ងួរសីហនាទទៅក្រាបទូលព្រះសម្មាសម្ពុទ្ធថាៈ អញចាស់ជរាទន់ទោរជាខ្លាំង ដោយសារអញមិនបានឃើញនូវព្រះរូបព្រះសាស្តាក្នុងរយៈវេលា ៧ ឆ្នាំ ហើយអញតែងចាត់ឲ្យស្វែងរកព្រះសម្ពុទ្ធគប់ទិវារាត្រីមិនដែលដាច់, ឲ្យកូនអញត្រឡប់មកគ្រងប្រជារាស្ត្រនៃព្រះរាជអាណាចក្រ ដែលបានសោកព្រួយថប់ចំពោះកូនអញ ព្រោះប្រជារាស្ត្រទាំងអស់ខ្វាបកូនអញមរណៈមុន មិនបានឃើញមុខកូនអញ ” ។ (មានត)

## គុណនៃការស្នេហាជាតិ

ស្រឡាញ់អ្វីពុំប្រសើរស្មើនឹងស្រឡាញ់ជាតិ
ព្រោះជាគុណអាចរាតត្រដាងហួសសាធារណ៍ទៅ
ផ្សាយពេញផែនខែត្រខែនដល់ជាតិខ្មែរទោះល្ងង់ខ្លៅ
ដោយចិត្តជ្រៅប្រុងស្ទួយជួយយកគោយានចាកអាយ័ត ។

យូរ - អ៊ុន

# សម្មាទិដ្ឋិកថា

## ព្រះអាចារ្យ អាំ-សាម៉ុល វត្តមហាមន្ត្រី ភ្នំពេញ

ទេសនាដាក់វិទ្យុឃោសនសព្ទនៃប្រទេសកម្ពុជា កាលពីថ្ងៃ ១៤ រោចខែកត្តិកឆ្នាំកុរនព្វស័ក
ព. ស. ២៤៩០ ត្រូវនឹងថ្ងៃ ១២ ធ្នូ ឆ្នាំ ១៩៤៧

### នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ ចំពោះព្រះអរហំសម្មាសម្ពុទ្ធជាម្ចាស់ ព្រមទាំងព្រះសទ្ធម្មនឹងព្រះសង្ឃ ដោយសេចក្ដីគោរព ។

ពេលនេះ អាត្មាភាពត្រូវវេនសំដែងធម្មទេសនាផ្សាយតាមវិទ្យុសព្ទ អាត្មាភាពនឹងសំដែងអំពី សម្មាទិដ្ឋិ គឺអង្គទី១ ក្នុងអដ្ឋង្គិកមគ្គ ដើម្បីចែកជូនពុទ្ធសាសនិកជន ដូចតទៅនេះ :—

ទិដ្ឋិ ប្រែថា "សេចក្ដីយល់ឃើញ"; សម្មា ប្រែថា "ប្រពៃ, ត្រូវ" សម្មាទិដ្ឋិ ប្រែថា "សេចក្ដីយល់ឃើញត្រូវ, យល់ឃើញប្រពៃ" ។ សម្មាទិដ្ឋិនោះ បានខាងបញ្ញា ដែលជាសោភនចេតសិកដ៏ក្លា ហានតោងយកព្រះនិព្វានមកជាអារម្មណ៍ ដឹងច្បាស់ក្នុងអរិយសច្ច-ទាំង ៤ មានទុក្ខសច្ចជាដើម ហើយប្រតិបត្តិដកគាស់រំលើងបង់នូវអវិជ្ជានឹងតណ្ហាឲ្យអស់ទៅ ។ សម្មាទិដ្ឋិនេះជាគូសត្រូវ ឬជាទំនាស់នឹងមិច្ឆាទិដ្ឋិ ។ ឯមិច្ឆាទិដ្ឋិ ប្រែថា "សេចក្ដីយល់ឃើញខុស,

ពុំឃើញប្រពៃ" ។ ដែលពុំឃើញប្រពៃដូច្នេះតើមកអំពីអ្វី? គឺមកតែអំពីអវិជ្ជា ។ ឯសម្មាទិដ្ឋិ ដែលថាយល់ឃើញត្រូវនោះ ព្រោះមានវិជ្ជា ។

ចុះអវិជ្ជាជាឈ្មោះរបស់អ្វី? វិជ្ជាជាឈ្មោះរបស់អ្វី? ទោសនឹងអានិសង្សរបស់អវិជ្ជានឹងវិជ្ជានោះដូចម្ដេច?

អវិជ្ជាជាឈ្មោះរបស់សេចក្ដីមិនចេះដឹង, សេចក្ដីមិនចេះមិនដឹង ហៅថា សេចក្ដីល្ងង់, បើមិនចេះអក្សរនឹងលេខ ហៅថា ល្ងង់ក្នុងអក្សរនឹងលេខ, មិនចេះធ្វើការណា ហៅថា ល្ងង់ក្នុងការនោះ, បើមិនចេះគិត ហៅថា ល្ងង់ក្នុងការគិត, អ្នកណាមានសេចក្ដីល្ងង់ អ្នកនោះឈ្មោះថាមនុស្សឥតមានចំណេះវិជ្ជា, អ្នកណាឥតមានចំណេះវិជ្ជា អ្នកនោះឈ្មោះថាមនុស្សល្ងង់ៗ នោះបើនឹងធ្វើការអ្វី ការនោះច្រើនតែមិនកើត បើទុកជាកើតក៏ច្រើនតែមិនល្អ, បើនឹងនិយាយពាក្យណា ពាក្យនោះច្រើនមិនប្រាកដ, បើនឹងគិតហេតុណា ហេតុនោះមិនចេញមកសំដែងឲ្យប្រាកដ. ថាខុស ឬត្រូវបានទេ ។ មនុស្សល្ងង់ឧបមាដូចមនុស្សខ្វាក់ ធម្មតាមនុស្សខ្វាក់ក្រមែងនឹងដើរតាមផ្លូវឲ្យត្រង់នឹងរហ័សឆាប់បានឡើយ ព្រោះមានសេចក្ដីញញើតញញើមរញ្ញួកស្ទាក់ស្ទើរក្នុងចិត្តជានិច្ច ម្ល៉ោះហើយសេចក្ដីមិនប្រាកដក្នុងចិត្តនោះ ធ្វើដំណើរមិនឲ្យប្រាកដថាទៅមុខ ឬទៅខាង ច្រើនទិសទាសដូចគ្នានឹងមនុស្សល្ងង់ បើនឹងធ្វើ ឬនិយាយ ឬគិត ក៏ឥតមានប្រាកដក្នុងចិត្ត. សេចក្ដីមិនប្រាកដនេះឯង មិនអាចនឹងធ្វើប្រយោជន៍ដែលខ្លួនត្រូវការឲ្យសម្រេចបានឡើយ ។

មានពុទ្ធភាសិតមួយកន្ទែងសំដែងថា: មោហៈគឺសេចក្ដីល្ងង់ បើមានច្រើនក្នុងសន្ដានចិត្តអ្នកណាមួយហើយ អាចនឹងធ្វើអ្នកនោះមិនឲ្យស្គាល់សេចក្ដីអាក្រក់ល្អនឹងការខុសត្រូវបានឡើយ ។

មានសុភាសិតមួយបទទៀតសំដែងថា

វិជ្ជាវិសេសលើសទ្រព្យធន ចោរមិនអាចប្លន់ឆក់លួចបាន
វិជ្ជាគ្មានថ្លៃនឹងប្រមាណ ប្រើចេះតែបានគ្រប់វេលា ។

បណ្ដាទ្រព្យសម្បត្តិទាំងអស់ដែលមានក្នុងលោកនេះ ទោះជារបស់ឥតវិញ្ញាណដូចយ៉ាងលុយកាក់ប្រាក់កាសកែវកងជាដើមក្ដី ទោះជារបស់មានវិញ្ញាណដូចយ៉ាងខ្ញុំកំដរប្រុសស្រីគោក្របីសេះដំរីជាដើមក្ដីវិជ្ជាចំណេះការចេះដឹងក្នុងអក្សរ ក្នុងលេខនព្វន្តគុណហារ ក្នុងភាសាជនជាតិតាងប្រទេសផ្សេងៗ ក្នុងការគូរពាក់សឆ្លាក់ក្បូរក្បាច់រចនា ចំណេះវិជ្ជាខាងហត្ថកម្មកសិកម្មវណិជ្ជកម្មជាដើមនេះឯង ប្រសើរវិសេសថ្លៃថ្លាជាងទ្រព្យសម្បត្តិគ្រប់មុខ ដែលជាទ្រព្យឥតវិញ្ញាណមានវិញ្ញាណនោះវិញ ព្រោះជាទ្រព្យសម្បត្តិទាំងនោះ មិនជារបស់មានខ្លឹមសារឋិតថេរយូរប៉ុន្មាន គង់មានវិនាសទៅដោយភ័យច្រើនប្រការ ដូចយ៉ាងភ័យអំពីចោរលួចប្លន់ឆក់ដណ្ដើម, ភ័យអំពីភ្លើងឆេះផ្ទះសម្បែង, ភ័យអំពីទឹកលិច, ឬវិនាសទៅដោយល្បែងបៀរប៉ោជាដើម ។ ឯចំណេះវិជ្ជានេះ ផុតស្រឡះអំពីភ័យទាំងឡាយមានចោរភ័យជាដើមនោះ គឺថាភ័យទាំងឡាយមានចោរភ័យ

ជាដើមនោះមិនអាចនឹងបៀតបៀនចំណេះវិជ្ជា ដោយការលួចប្លន់ឆក់ដណ្ដើម ក៏ហែងគម្រាមម្ចាស់ចំណេះវិជ្ជានោះបានឡើយ ដោយហេតុនេះហើយបានជាពោលថា ចំណេះវិជ្ជានោះវិសេសថ្លៃថ្លាជាងទ្រព្យសម្បត្តិទាំងអស់ ។

ម្យ៉ាងទៀត ចំណេះវិជ្ជានេះនឹងកាត់ថ្លៃថាមានដំឡៃប៉ុណ្ណេះប៉ុណ្ណោះមិនទាំងបានផង, ព្រោះថាជនណាមួយជាអ្នកមានទ្រព្យសម្បត្តិធនធានច្រើន តែជាអ្នកខ្ជិលច្រអូសក្នុងការរៀនសូត្រ ជននោះចង់បានចំណេះវិជ្ជាហើយយកប្រាក់កាសមានចំនួនច្រើនពាន់ច្រើនហ្មឺន ទៅដូរប្ដូរទិញចំណេះវិជ្ជានោះអំពីអ្នកណាមួយ ហើយបង្ខំនឹងធ្វើចំណេះវិជ្ជានោះឲ្យវាតែចូលទៅក្នុងមាត់ឬក្នុងពោះ ដោយមិនបាច់រៀនសូត្រនោះមិនបានឡើយ កុំថាតែគ្រប់អ្នកមានចំណេះវិជ្ជានោះ នៅជាបុថុជ្ជនដូចយ៉ាងយើងរាល់រូបឡើយ សូម្បីតែព្រះលោកនាថជាម្ចាស់ ដែលព្រះអង្គជាឯកអគ្គបុគ្គលជាឧត្តមជន ជាអង្គអរហន្តយ៉ាងថ្លៃថ្លា វិសេសទាំងអម្បាលហ្នឹង ក៏ព្រះអង្គមិនអាចនឹងចាប់ទាញចំណេះវិជ្ជាជាលោកិយឬលោកុត្តរៈ ប្រែកបញ្ចូលឲ្យចូលទៅក្នុងមាត់ឬក្នុងពោះនៃមនុស្សខ្ជិលនោះបានទេ កុំថាដល់ទៅចំណេះវិជ្ជាដែលធំៗ ដែលថ្លៃថ្លានោះឡើយ សូម្បីតែកំទេចកំទីចំណេះវិជ្ជា ដែលជារបស់ទន់ទាបថោកថយ នោះនឹងយកប្រាក់ចំនួនពាន់ហ្មឺនទៅទិញក៏ពុំបាន តែខ្ជិលរៀនហើយកុំសង្ឃឹម មុខជាខានបានវិជ្ជា ។

ដោយហេតុនេះហើយបានជាថាចំណេះវិជ្ជាកាត់ថ្លៃមិនបាន ។ ម្យ៉ាងទៀត ទ្រព្យសម្បត្តិទាំងពួងប្រើចេះតែអស់ទៅៗ តិចទៅៗ, បើមិនរកថែមទៀត បានតែខាងចាយម្យ៉ាងនោះ គង់មុខជាខានប្រើប្រាស់ ។ ឯចំណេះវិជ្ជាវិញមិនដូច្នោះទេ ប្រើច្រើនទៅក៏រឹងរឹតតែចំរើនឡើងៗ មិនចេះថយ មិនចេះស្រុត មិនចេះអស់, ដូចអ្នកចេះចំណេះវិជ្ជាខាងច្បាប់ទម្លាប់, អ្នកនោះ បើបានទៅសំដែងប្រាប់ឬពន្យល់អ្នកណា ឬទៅបង្រៀនគេហើយ ច្បាប់ទម្លាប់នោះ ក៏រឹងរឹតតែចាំស្ទាត់ប្រាកដឡើង រឹងរឹតតែបែកព្រោងព្រាតឡើង; ឬក៏ដូចជាអ្នកចេះអក្សរកាព្យឃ្លោង, អ្នកនោះបើបានសំដែងប្រាប់ពន្យល់ ឬតែងញឹកញយហើយ អក្សរនឹងកាព្យឃ្លោងនោះ ក៏រឹងរឹតតែស្ទាត់ជំនាញសរសេររហ័សរហួន ឯកាព្យឃ្លោងកាន់តែពីរោះឡើងៗ បែកឡើងៗ លែងចាំបាច់នឹកនា គ្រាន់តែថាបានៗ ។ ដោយហេតុនេះហើយបានជាថា ចំណេះវិជ្ជាប្រើមិនចេះអស់ទេ ចេះតែចំរើនទៅខាងមុខជានិច្ច ។

មិនតែប៉ុណ្ណោះ ចំណេះវិជ្ជាអាចផ្តល់ប្រយោជន៍ឲ្យគ្រប់ពេលវេលា ដោយហេតុនេះហើយ បានជាថាចំណេះវិជ្ជានេះជាមិត្តទីមួយ របស់មនុស្សប្រុសស្រី ។ មួយវិញទៀត ចំណេះវិជ្ជាអាចនឹងធ្វើអ្នកទ្រទ្រង់ឲ្យគេកោតខ្លាចគោរពប្រណិប័តន៍ គឺថាជនណាមួយដែលមានពូជពង្សថោកទាប ឬមានរូបកិលវិការៈយ៉ាងណាក៏ដោយ បើមានចំណេះវិជ្ជា

ចេះជ្រៅជ្រះក្បោះក្បាយហើយ ជននោះបើទៅកន្លែងណាមួយចំណេះវិជ្ជានេះ ក៏ហាក់ដូចជាទៅទាញមនុស្សប្រុសស្រីឲ្យក្រោកចាកទីកន្លែងឡើង គោរពប្រណិប័តន៍កោតក្រែងចំពោះជននោះឯង ។

ម្យ៉ាងទៀតចំណេះវិជ្ជានេះ អាចនឹងធ្វើមនុស្សម្នាក់ឲ្យមានដំឡៃស្មើនឹងមនុស្សមួយពាន់នាក់មួយម៉ឺននាក់ ឬច្រើនជាងនេះទៅទៀត សេចក្តីនេះយ៉ាងណា? ជាដូចជាអ្នកណាមួយ ដែលគេចេះចំណេះផ្លូវលោកផ្លូវធម៌សព្វគ្រប់គ្មានចន្លោះ ព្រមទាំងចំណេះវិជ្ជាសម្រាប់ស្រុកប្រទេសរបស់ខ្លួន នឹងចំណេះវិជ្ជាសម្រាប់តាំងប្រទេសផ្សេងៗ ហើយអ្នកនោះក៏បានទទួលនូវឥស្សរភាពជាធំ បើប្រសិនជាមានកំហុសអ្វីគួរដល់បព្វាជនីយ-កម្មក្តី គួរផ្តាច់បង់ជីវិតក្តី, មនុស្សប្រុសស្រីទាំងឡាយ ទាំងពាន់ម៉ឺននាក់គួរប្រថុយជីវិតប្តូរជំនួសមនុស្សម្នាក់នេះដែរ នេះដោយហេតុអ្វី? គឺដោយហេតុតែចំណេះវិជ្ជានេះហើយ ដែលធ្វើមនុស្សម្នាក់ឲ្យមានដំឡៃ ប្រ-ហែលនឹងមនុស្សទាំងពាន់ទាំងម៉ឺននាក់នេះឯង គួរឲ្យអស្ចារ្យណាស់ហ្ន៎! ចំណេះវិជ្ជានេះមានគុណប្រយោជន៍ច្រើនប្រការណាស់ ដោយហេតុនេះហើយ គួរតែសាធុជនប្រុសស្រីក្មេងចាស់គ្រហស្ថបព្វជិត ខំស្វះស្វែងរករៀនចំណេះវិជ្ជាផ្លូវលោកផ្លូវធម៌ ឲ្យបានចេះដឹងគ្រប់ៗ គ្នាឡើង កុំគប្បីធ្វេសប្រហែសឡើយ ។

ម្យ៉ាងទៀតអ្នកដែលមានកូន ត្រូវរំឭកដាស់តឿនកូនឲ្យរៀនចំណេះវិជ្ជាឲ្យបានចេះដឹងឡើង ព្រោះកូនដែលគ្មានចំណេះវិជ្ជា ជាមនុស្ស

ល្អមិនប្រព្រឹត្តតាមច្បាប់ នឹងមានប្រយោជន៍អ្វីដោយសារកូនដូច្នោះ ប្រៀបឧបមាដូចភ្នែកខ្វាក់ នឹងមានប្រយោជន៍អ្វីដោយភ្នែកខ្វាក់នោះ មានតែសេចក្ដីអផ្សុកព្រួយចិត្តតែម្យ៉ាង ។

កូនមាន ៣ គឺកូនដែលមិនទាន់កើត ១, កូនដែលកើតហើយស្លាប់បាត់ទៅវិញ ១, កូនដែលកើតហើយនៅរស់ តែជាមនុស្សល្ងង់ខ្លៅ ១, បណ្ដាកូនទាំង ៣ នេះ គួរយកកូន ២ ខាងដើម ព្រោះថាបើមានទុក្ខព្រួយក៏មានតែមួយលើកក៏បាត់ទៅ, ឯកូនមួយទីបំផុតនោះមិនគួរយកឡើយ ព្រោះកូននោះនឹងនាំបណ្ដាលឲ្យមានសេចក្ដីទុក្ខព្រួយជានិច្ច ។

ក្នុងគម្ពីរលោកនីតិបករណៈសំដែងថា ៖

មានកូនមិនឲ្យកូនសូត្ររៀន ចំណេះរបៀនការនានា
មាតាលោកថាជាវេរ បិតាទុកជាសត្រូវធំ ។
កូនពេញរូបពាលពត់មិនឡើង ហៅថាមិនថ្កើងក្នុងជំនុំ
ប្រៀបដូចកុកក្រោងចូលទ្រនំ កណ្ដាលជំនុំនៃរាជហង្ស ។

ដែលនាំសុភាសិតខ្លះមកទុកក្នុងទីនេះ ដើម្បីឲ្យឃើញថា សេចក្ដីល្ងង់នេះ បើកើតមានដល់អ្នកណាហើយ នឹងត្រឡប់ទៅជាទោស ធ្វើអ្នកនោះឲ្យបានដល់នូវសេចក្ដីមិនចំរើន នឹងទន់ទាបថយថោក តាំងពីជាតិនេះដរាបដល់ជាតិខាងមុខ ។ ឯទោសនៃសេចក្ដីល្ងង់ដែលនឹងឃើញក្នុងជាតិនេះ ដូច្នេះ :—

១ – បើល្ងង់ក្នុងវិធីអក្សរ គឺមិនចេះសរសេរ មិនចេះមើល ទីងនាំឲ្យខាតបង់នូវប្រយោជន៍ដូច្នេះ គឺមិនអាចមើលសាស្ត្រា ឬសៀវភៅដែលមានច្បាប់ប្រដៅនាំឲ្យកើតគំនិតប្រាជ្ញា ឬមិនអាចសរសេរសំបុត្រកត់ហេតុណាមួយ ដែលខ្លួនត្រូវការផ្ញើទៅញាតិមិត្តបាន ។

២ – អ្នកដែលមិនមានចំណេះវិជ្ជាអ្វី បើនៅអាស្រ័យជ្រកកោនក្នុងសំណាក់អ្នកធំហើយ ចេះគោរពប្រណិប័តន៍យ៉ាងណាក៏ដោយ អ្នកធំនោះក៏មិនអាចលើកតំកើងអ្នកនោះ ឲ្យមានគេ្គរឈ្មោះយសស័ក្តិបានឡើយ ព្រោះលោកយល់ថាជាមនុស្សល្ងង់ បើគ្រាន់បើណាស់ បានត្រឹមតែសេចក្តីសុខជាន់ទាបប៉ុណ្ណោះ តែក៏គង់មិនរួចអំពីទីជាអ្នកបំរើគេដែរ ។

៣ – មនុស្សល្ងង់នោះ បើមានយសស័ក្តិ ដោយអំណាចព្រេងសំណាងជួយឧបត្ថម្ភ បើនិយាយការអ្វីទៅរកគេ គេពុំសូវជឿតាមពុំកោតខ្លាច ព្រោះគេដឹងថា ខ្លួនជាមនុស្សល្ងង់ ។

៤ – មនុស្សល្ងង់ ជាមនុស្សខ្វះមិត្តសំឡាញ់ ព្រោះគេមិនសូវត្រូវការយកខ្លួនធ្វើជាមិត្តសំឡាញ់ឡើយ ព្រោះហេតុអ្វី? ព្រោះគេដឹងថាខ្លួនជាមនុស្សល្ងង់ បើនឹងពឹងរកយកទៅធ្វើការអ្វី ឬជួយពិគ្រោះការអ្វីក៏មិនកើតទាំងអស់ បើខ្ញុំណាជាមានមិត្តសំឡាញ់ ក៏ច្រើនតែបានមិត្តសំឡាញ់ដែលជាមនុស្សល្ងង់ដូចគ្នា ។

៥ – មនុស្សល្ងង់បើជាអ្នករកស៊ី ក៏មិនអាចនឹងធ្វើសម្បត្តិឲ្យចំរើនដូចអ្នកដែលចេះដឹងបានឡើយ ព្រោះខ្លួនមិនស្គាល់កាលគួរនឹងកាលមិនគួរ ។

៦ – មនុស្សល្ងង់មិនដែលបានសេចក្ដីសរសើរ អំពីសំណាក់អ្នកប្រាជ្ញណាមួយដល់ម្ដងឡើយ បើបានសរសើរខ្លះតែអំពីសំណាក់នៃមនុស្សល្ងង់ជាងខ្លួន ៗ ពោលនៃសេចក្ដីល្ងង់សន្ធើបខ្លីតែប៉ុណ្ណោះ ៗ

អានិសង្សនៃការចេះដឹង ដែលឃើញច្បាស់ក្នុងជាតិនេះ ដូច្នេះ :–

១ – បើចេះវិធីលេខឬអក្សរ គឺចេះសរសេរឬមើល នឹងនាំឲ្យមានប្រយោជន៍អាចមើលសាស្ត្រាឬសៀវភៅ ដែលជាច្បាប់ប្រដៅ នាំឲ្យកើតគំនិតប្រាជ្ញា ឬអាចសរសេរសំបុត្រកត់ហេតុណានីមួយ ដែលខ្លួនត្រូវការផ្ញើទៅញាតិមិត្របាន ៗ

២ – អ្នកដែលមានចំណេះវិជ្ជា បើនៅធ្វើការក្នុងសំណាក់អ្នកធំដោយយកចិត្តទុកដាក់ អ្នកធំនោះលោកនឹងស្រឡាញ់រាប់អាន ហើយអាចទំនុកបំរុងឲ្យមានកេរ្តិ៍ឈ្មោះ យសស័ក្តិចំរើនថ្កើនឡើងបាន ព្រោះលោកយល់ថាខ្លួនមានចំណេះវិជ្ជា ៗ

៣ – អ្នកមានចំណេះវិជ្ជា បើជាអ្នកមានយសស័ក្តិ ក៏មានសេចក្តីចំរើនរុងរឿងក្នុងទីប្រជុំ បើនិយាយការអ្វីៗ គេក៏ជឿស្តាប់តាម ព្រោះគេយល់ថាជាអ្នកចេះ ៗ

៤ – អ្នកចេះ ជាមនុស្សសម្បូណ៌ទៅដោយមិត្រសំឡាញ់ ព្រោះថាអ្នកឯទៀតគេច្រើនត្រូវការយកអ្នកមានចំណេះវិជ្ជានោះ ធ្វើជាទីពឹងក្នុងពេលដែលមានកិច្ចធុរៈអ្វីៗ បាន ៗ

៥ – អ្នកចេះ បើតាំងខ្លួនជាអ្នករកស៊ីតាមធម្មតាវិញ ក៏មានសេចក្ដីចំរើនក្នុងការរកស៊ីនោះ ព្រោះជាអ្នកមានគំនិតចេះគិតស្គាល់ទំនងនៃការរកស៊ី មានស្គាល់ការគួរនិងមិនគួរជាដើម ។

៦ – អ្នកមានចំណេះវិជ្ជា រមែងបាននូវសេចក្ដីសរសើរ អំពីសំណាក់អ្នកប្រាជ្ញជាច្រើនៗ ។

ហេតុដូច្នេះ អស់លោកទាំងឡាយគួរខ្មែរ គួរស្អប់សេចក្ដីល្ងង់ កុំបណ្ដោយចិត្តឲ្យសេចក្ដីល្ងង់ចូលមកលុកលុយបានឡើយ គួរតាំងសេចក្ដីព្យាយាម ប្រឹងប្រែងស្វះស្វែងរករៀនចំណេះវិជ្ជា មកទុកដាក់ក្នុងខ្លួន ដើម្បីនឹងបំបាត់បង់នូវសេចក្ដីល្ងង់ចេញបន្តិចម្ដងៗ ជាលំដាប់តទៅ ។

វិជ្ជាជាឈ្មោះរបស់សេចក្ដីចេះដឹង បើអ្នកណាមានចំណេះវិជ្ជាហើយ អ្នកនោះរមែងបាននូវអានិសង្សដូចពណ៌នាមកនេះ ។ ហេតុដូច្នេះ បួរពួកយុវជន យុវនារីទាំងឡាយ ខំរករៀនចំណេះវិជ្ជា ឲ្យបានចេះដឹងមាំមួនដើម្បីនឹងជួយជ្រោមជ្រែងជាតិ សាសនា មហាក្សត្រ របស់យើងឲ្យបានចំរើនរុងរឿង ឲ្យបានដើរទាន់សម័យនឹងគេឡើង ។

អាត្មាភាពសំដែងអរិយមគ្គទី ១ គឺសម្មាទិដ្ឋិ ចប់ដោយសង្ខេបតែប៉ុណ្ណេះ ។

# រឿងមនុស្សថ្ម

លោកផេង-ជឿរ សាស្ត្រាចារ្យ នៅសាលាគរុវិជ្ជា ភ្នំពេញ

ប្រែពីសៀវភៅ «កុង អេ ឡេហ្សង់ ឌុយប៉េអ៊ី រូម៉ាំងត្រាឌីប៉ាអេ អាដាប្តេ ប៉ា ប.នរទីន»

---

កន្លងកាលដ៏កន្លងទៅយូរអង្វែងហើយ. ព្រះរាជាមួយព្រះអង្គ មានមហេសីពីរព្រះអង្គនៅក្មេង ៗ ទ្រទ្រង់នូវព្រះរូបឆោមឆាយាស្អាតល្អដូចគ្នា តែមិនមានព្រះរាជបុត្រ ។

ថ្ងៃមួយ មានព្នងខ្មៅម្នាក់ចូលមកក្រាបថ្វាយបង្គំព្រះរាជា ហើយទូលថា: "បពិត្រព្រះមហារាជដ៏ទ្រង់យស! ទូលព្រះបង្គំបានដឹងថាព្រះអគ្គមហេសីគ្មានព្រះរាជបុត្រ បើដូច្នេះ សូមឲ្យព្រះនាងសោយទឹកស្មៅនេះ នោះព្រះនាងនឹងមានព្រះរាជបុត្រជាប្រាកដ" ។ ព្រះរាជាទ្រង់ប្រទានសេះមួយយ៉ាងល្អ នឹងសំពត់អាវដ៏មានតម្លៃដល់ព្នងនោះ ហើយទ្រង់ប្រទានថ្នាំនោះឲ្យទៅព្រះមហេសី ។ ព្រះនាងទ្រង់មានព្រះសុរនីយ៍ហៅនាយពិសេសស្ត្រីម្នាក់មក ហើយប្រគល់ស្មៅនោះឲ្យយកទៅស្ងោយកទឹកថ្វាយទ្រង់ តែមិនបានប្រាប់រឿងហេតុនៃថ្នាំនោះទេ ។ នាងពិសេសក៏ធ្វើតាមព្រះរាជបញ្ជា ហើយមុននឹងយកទឹកឱសថមកថ្វាយព្រះនាង ស្រីបំរើក្រេបមើលបន្តិច ។ លុះកាលកន្លងទៅ ព្រះអគ្គមហេសីនឹងនាងពិសេសប្រសូតបានកូនប្រុសមួយម្នាក់ល្អៗដូចគ្នា មួយឈ្មោះទាជិន មួយឈ្មោះ អារិន ។

ថ្ងៃមួយ ព្រះរាជាទ្រង់យាងចេញទៅធ្វើសឹកសង្គ្រាម ប្រទានសិទ្ធិឲ្យព្រះរាជបុត្រជាអ្នកគ្រប់គ្រងស្នងព្រះអង្គ ប្រគល់កូនសោមួយបង្កោមធំឲ្យផង ហើយទ្រង់មានព្រះបន្ទូលថា: "ម្នាលកូនសំឡាញ់ឪពុក! កូនសោទាំងប៉ុន្មាននេះអាចចាក់បើកបន្ទប់បានទាំងអស់ ហើយកូនអាចចូលបានគ្រប់ ៗ ប៉ុន្តែ បន្ទប់មួយដែលចាក់បើកបានដោយកូនសោមាស កូនកុំចូលក្នុងបន្ទប់នោះឲ្យសោះ ព្រោះបើកូនឯងចូលក្នុងបន្ទប់នោះ សេចក្តីទុក្ខនឹងមានដល់ខ្លួន" ។

ខាងក្រោយការធ្វើដំណើរចេញទៅនៃព្រះរាជា ព្រះរាជកុមារយាងទតគ្រប់បន្ទប់ផ្សេងៗ ទាំងអស់ ទ្រង់ប្រទះសុទ្ធតែគំនរត្បូងពេជ្រយ៉ាងធេតៗ ប៉ុន្តែសម្បត្តិទាំងនេះ ទ្រង់គ្មានត្រូវការសោះ ។ ទ្រង់ឈរឈប់នៅមុខបន្ទប់កូនសោមាស ហើយនឹកដល់ព្រះរាជឱង្ការនៃព្រះវរបិតា ។ អខន្តីធម៌បេះតែទន្ទ្រានលុកលុយក្នុងចិត្តព្រះរាជកុមារៗ ក៏ចូលក្នុងបន្ទប់ដែលហាមនោះ, ក្នុងបន្ទប់នោះមានវ៉ែនតាកែវចរណៃមួយ ។ កាលណាព្រះរាជកុមារទតក្នុងវ៉ែនតា ទ្រង់បានឃើញប្រាសាទមួយជាវិការនៃមាសភ្លឺចិញ្ចាចចិញ្ចែងជាងពន្លឺថ្ងៃ ។ ក្នុងប្រាសាទនោះ មានព្រះរាជធីតាមួយព្រះអង្គព្រះនាម "កល្យាណី" ល្អដូចស្រីទេពអប្សរ ។

ព្រះរាជកុមារទ្រង់ទតសំឡឹងក្នុងវ៉ែនតាអស់អំឡុងជាយ៉ាងយូរ ទើបដាក់វ៉ែនតាចុះត្រង់កន្លែងដើម ហើយយាងចេញចាកបន្ទប់កូនសោមាស ដោយមានព្រះភក្ត្រពោរពេញដោយព្រះជលនេត្រ ។

ព្រះរាជាមានជ័យកាលណា ទ្រង់ស្តេចត្រឡប់មកវិញពុំហានបង្អង់, ប៉ុន្តែលុះស្តេចមកដល់ ព្រះអង្គមិនឃើញព្រះរាជបុត្រសំឡាញ់ចេញមកទទួលព្រះអង្គដោយសេចក្តីរីករាយ ឃើញតែព្រះវររាជជាយាតែម្នាក់ឯងចេញមកទទួល ។ ព្រះអគ្គមហេសីក្រាបបង្គំទូលថា: ព្រះរាជកុមារទ្រង់ប្រឈួន ។ ព្រះរាជាទ្រង់ជ្រាបក្នុងព្រះហ្ឫទ័យមួយរំពេចនូវហេតុនៃការប្រឈួននោះ ទើបទ្រង់ឲ្យគេហៅអស់គ្រូពេទ្យយ៉ាងជំនាញមក, ប៉ុន្តែគ្រូពេទ្យទាំងនោះក្រាបបង្គំទូលថា: ព្រះរាជកុមារលុះតែបានព្រះនាងកំឡាលីណា មកធ្វើជាព្រះអគ្គទេពី ទើបជាសះស្បើយ ។ ព្រះចៅទ្រង់បញ្ជូនទូតបន្តកន្ទុយគ្នា ដើម្បីយកដំណឹងអំពីសំណាក់នាងកំឡាលី-ណា ប៉ុន្តែជាកិច្ចឥតអំពើ ព្រោះព្រះវររាជបិតានៃព្រះនាងមិនចង់ឲ្យព្រះនាងមានព្រះស្វាមី ។

លុះបានដំណឹងអនិដ្ឋារម្មណ៍ដូច្នេះ ព្រះរាជកុមារសម្រេចក្នុងព្រះហ្ឫទ័យថា នឹងស្តេចទៅដណ្តឹងព្រះនាងដោយព្រះអង្គឯង ។ រួចទ្រង់បានមានបន្ទូលប្រាប់ការិនជាសំឡាញ់ នូវរឿងហេតុខាងលើនេះ ដែលជាការបណ្តាលឲ្យទ្រង់មានទុក្ខយ៉ាងធ្ងន់ ។ ថ្ងៃមួយជនទាំងពីរនាក់ ក៏ធ្វើដំណើរចេញទៅ ទោះបីព្រះរាជបិតា-មាតាឃាត់យ៉ាងណាក៏មិនស្តាប់ ។ ជនទាំងពីរត្រេចរង្គាត់លេចកាលចូលព្រៃ លេចព្រៃចូលកាល អស់អំឡុងថ្ងៃនឹងខែដ៏យូរ ទើបបានដល់ខ្ទមយាយចាស់ម្នាក់ ឈ្មោះ គីរ៉ាត ។

ព្រះអង្គម្ចាស់គោះទ្វារ, យាយចាស់ចេញមក ហើយសួរសាកសួរដំណើរ ដើមទងសព្វគ្រប់ប្រការ, ព្រះអង្គម្ចាស់ទ្រង់សុំខ្ទមគាត់សំណាក់មួយយប់ ទំរាំដល់ព្រឹកហើយឲ្យគាត់ប្រាប់ផ្លូវ ដែលទៅកាន់ព្រះរាជរដ្ឋាព្រះអង្គម្ចាស់ក្សត្រីព្រះនាមកីឡាលីណាផង ។

យាយចាស់ឃើញកុមារទាំងពីរក៏មានចិត្តមេត្តាករុណា ហើយនិយាយថា: នែចៅ! យាយឲ្យចៅឯងចូលសំណាក់នៅនេះបានក្នុងមួយយប់ ប៉ុន្តែយាយខ្លាចក្រែងកាលណាកូនយាយមក វាធ្វើចៅឯងឲ្យក្លាយទៅជាដុំថ្មកកក ។ បើដូច្នេះចូរចៅទៅឯផ្ទះប្អូនស្រីរបស់យាយវិញល្អជាជាង ព្រោះគាត់ប្រហែលនឹងអាចធ្វើនូវបដិសណ្ឋារៈដល់ចៅបានហើយអាចបង្ហាញផ្លូវឲ្យទៀតផង ។

ព្រះរាជកុមារធ្វើដំណើរទៅទៀត បានដល់ផ្ទះយាយម្នាក់ឈ្មោះគោធរាត ប៉ុន្តែទ្រង់មិនអាចឈប់នៅទីនោះបានយូរ រួចស្តេចទៅដល់ខ្ទមយាយ ហិមរាត ។ ព្រះរាជកុមារគោះទ្វារហៅ, ស្រីម្នាក់រាងស្តើងរូបស្អាតបាតបើកទ្វារចេញមក លុះឃើញព្រះរាជកុមារ ក៏មានវាចាថា: "បពិត្រព្រះអង្គម្ចាស់ហាវហាន! ទូលព្រះបង្គំដឹងជាមុនថា ទ្រង់ត្រូវការទៅដណ្តឹងព្រះនាងកីឡាលីណា ប៉ុន្តែលុះតែទ្រង់ប្រស្រ័យជាមួយនឹងកូនទូលព្រះបង្គំ ទើបអាចស្តេចទៅដល់នគរព្រះនាងបាន ។ បើដូច្នេះ សូមទ្រង់សំណាក់ក្នុងទីនេះជាមួយនឹងសំឡាញ់របស់ទ្រង់សិន ។ ប៉ុន្តែត្រូវ

ទូលព្រះបង្គំយកទ្រង់ព្រមទាំងសំឡាញ់លាក់ឲ្យល្អត្រឹមត្រូវ បើពុំដូច្នោះទេ កាលណាកូនទូលព្រះបង្គំមកដល់ ហើយដឹងថាមានមនុស្សលោកនៅកន្លែងនេះ នោះពួកនឹងសំឡាប់ចោលជាអសារបង់ ។

ខណៈនោះ យាយហិមពាន្ត ទះដៃបីដង ស្រាប់តែសកុណាមាសក្អែកត្បូងមរកតដំបពុះត្បូងពេជ្រហើរលោតចុះមក យកស្លាបទាំងសងខាងគ្របក្រោបកុមារទាំងពីរ ហើយហើរស្ទុះលោតឡើងទៅលើទ្រនំវិញ ។

គ្រាន់តែកិច្ចការនេះរួចសព្វគ្រប់ហើយ គេឮស្នូរសន្ធឹកខ្យល់ត្រជាក់បក់មកមានទាំងក្លិនពិដោរផ្កាកូឡាប និងគិណ្ណជាតិផ្សេងៗ ដោយមកផងរួចទ្វារខ្ទមក៏របើកឯង គេឃើញមនុស្សកំឡោះម្នាក់រូបស្អាតដើរចូលមកសក់វែងក្រហម ស្លាបប្រាក់ ដៃកាន់ស្មៅនឹងផ្កាបុប្ផជាតិគ្រប់មុខ ។ ចូលមកដល់ស្ទើរតែមិនទាន់ពារស្រែកសួរថា: ម៉ែ! នៅទីនេះធុំក្លិនមនុស្សលោកម៉េះ? ។

– កូនសំឡាញ់! ឯងធុំក្លិនមនុស្ស តើមនុស្សមកធ្វើអ្វីនៅទីនេះ ។

ព្រះពាយនៅស្ងៀមវិញ ចាប់បរិភោគអាហារ ។ ខាងក្រោយដែលបានផឹកទឹកដោះពពែមួយកែវនឹងមេយំមួយចាន លោកនិយាយរឿងកំសាន្តលេងដោយសប្បាយតាមធម្មតា ជាមួយនឹងម្ដាយលោក ។

ម្ដាយឃើញឱកាសស្រួលហើយ សួរថា: ម្នាលកូន! ចូរឯងប្រាប់ម្ដាយតើព្រះរាជវង្សរបស់ព្រះនាង កីឡាលីណា នៅឯណា? ហើយម្យ៉ាងទៀតតើត្រូវធ្វើដូចម្ដេច ដើម្បីយកនាងធ្វើជាមហេសីបាន? ។

ព្រះពាយឆ្លើយថា: ឱលោកម្ដាយ! សំនួរនេះមិនល្អឡើយ ប្រាប់ទេ, ប៉ុន្តែណាហ៍យ ដើម្បីបំពេញទឹកចិត្តលោកម្ដាយ ខ្ញុំសូមជំរាបបន្តិចទៅចុះ ... ។

"ព្រះរាជរដ្ឋនៃព្រះរាជធីតា ព្រះនាម "កីឡាលីណា" នៅឆ្ងាយអនេកអនន្តពេក បើទៅដោយការធ្វើដំណើរតាមផ្លូវធម្មតា គេត្រូវដើរអស់រាប់ពាន់ឆ្នាំទើបបានដល់ ។ ប៉ុន្តែគេអាចទៅតែមួយប៉ប្រិចភ្នែកឲ្យបានដល់ ដោយកាត់តាមព្រៃកាឡូវេន ដែលនៅក្នុងទីនោះ មានជ្រោះទឹកលោហជាតិហូរបាញ់ចេញស្ទុះកៃដុំថ្មនឹងអណ្ដាតភ្លើងទៅដល់កណ្ដាលអាកាស ជ្រោះនោះគេត្រូវជិះលើដើមឈើមួយកំណាត់ ជារបស់ព្រាយទាំងឡាយដែលតែងឆ្លងជ្រោះនោះ ... ។

"ប៉ុន្តែ បើជនណាបានឮខ្ញុំនិយាយ ហើយនាំយកទៅប្រាប់អ្នកដទៃ, ជើងនៃជននោះនឹងត្រូវក្លាយជាថ្មរហូតដល់ជង្គង់ ... ។

"កាលណាបានទៅដល់ព្រះរាជរដ្ឋព្រះនាងហើយ អ្នកហ្នឹងបានត្រូវយកកំណាត់ឈើនោះ ធ្វើឲ្យក្លាយជាប្រើសមាស ហើយចូលពួនខាងក្នុង ដើម្បីឲ្យងាយបានទៅដល់ព្រះរាជដំណាក់នៃព្រះនាង នឹងលួចព្រះនាងមក ... ។

"ប៉ុន្តែ បើជនណាបានឮខ្ញុំនិយាយ ហើយយកទៅប្រាប់អ្នកដទៃ, ដងខ្លួននៃជននោះនឹងត្រូវក្លាយជាថ្មត្រឹមចង្កេះ ... ។

« កាលណាអ្នកហារហ៊ានបានសេពសម្ភពនឹងព្រះនាងហើយ យាយគីរ៉តឈឺចិត្ត នឹងបញ្ជូនឈ្មួញម្នាក់ឲ្យទៅលក់អាវទ្រនាប់ សរសៃយ៉ាងផ្ការផ្កាងសរសៃពីងពាង ។ ព្រះនាងក៏ឡាលណា នឹងទិញអាវទ្រនាប់នោះ, ហើយបើមុននឹងពាក់ ព្រះនាងមិនបានយកអាវនោះទៅជ្រលក់ក្នុងទឹកក្អែកសត្វលលកសិនទេ, នោះនឹងសុគតមួយរំពេច ក្នុងពេលដែលព្រះនាងគ្រាន់តែលើកអាវឡើងនឹងទ្រង់ . . . ។

« អ្នកណាដឹងរឿងនេះ ហើយយកទៅប្រាប់អ្នកដទៃ, ខ្លួននៃអ្នកនោះនឹងក្លាយជាថ្មតាំងពីជើងរហូតដល់ក្បាល » ។

ក្នុងរយៈពេលដែលព្រះពាយនិយាយរឿងនេះ ព្រះរាជកុមារទ្រង់ផ្ទំលក់ ប៉ុន្តែសំឡាញ់របស់ទ្រង់ដែលមិនដេក បានឮរឿងសព្វគ្រប់គ្មានសល់ ។

ភ្លឺឡើង ព្រះពាយចេញផុតទៅ ។ ទាជិនជាព្រះរាជបុត្រស្នួរម្ដាយព្រះពាយថា: តើយាយនឹងអាចប្រាប់ដំណឹងអ្វីខ្លះដែរឬ? ។ យាយហិមរ៉ត ខ្លាចក្រែងក្លាយខ្លួនទៅជាថ្ម ក៏ក្រាបបង្គំទូលព្រះរាជកុមារវិញថា: ខ្ញុំគ្មានបានអ្វីថ្វាយជាដំណឹងឡើយ ។

ខណៈនោះ កុមារទាំងពីរបានធ្វើដំណើរតទៅទៀតអស់កាលដ៏យូរ ៗ នៅពេលព្រះអាទិត្យជិតនឹងអស្ដង្គត មាណពទាំងពីរបានឮសំរែកដ៏ខ្លាំងគឺជាសូរគេស្ដាប់អ្វីមិនឮ ហើយបានឃើញជ្រោះទឹកលោហធាតុមួយ

យ៉ាងធំ ឆេះចេញអណ្តាតភ្លើងដែលផុះដុំច្រទៅលើរហូតដល់អាកាស ។ ព្រះរាជកុមារឃើញហេតុដ៏ប្លែកអស្ចារ្យដូច្នោះ មានព្រះហឫទ័យភិតភ័យមហិមា ។ ប៉ុន្តែ អារិនជាកូនមេទាយពិសេសក្រាបបង្គំទូលថា: សូមទ្រង់កុំព្រួយព្រះរាជហឫទ័យអ្វីឡើយសោះ សូមស្តេចយាងចូលក្នុងព្រៃនេះជាមួយនឹងទូលព្រះបង្គំ ហើយទ្រង់មិនធ្វើអ្វី ធ្វើតាមតែសេចក្តីបង្គាប់របស់ទូលព្រះបង្គំ ។

លុះដល់កណ្តាលកាឡូរ៉ែន អារិនបានឃើញដើមឈើមួយកំណាត់ផ្តេកដោលនៅនោះ ។ មាណពទាំងពីរនាក់នាំគ្នាជិះលើកំណាត់ឈើ ហើយគោះឈើនោះនឹងកែងជើងបីដង, កំណាត់ឈើក៏ក្លាយជារថមួយទឹម ដោយអស្សពាហ៍ន៍ដប់ពីរៗ ទាញរថនោះយ៉ាងលឿនដូចខ្យល់ទៅលើអាកាសវេហាស៍, រួចមួយស្របក់ ក៏ចុះចំពីខាងមុខទ្វារប្រាសាទព្រះនាងកីឡាលីណា ។

មាណពទាំងពីរនាំគ្នាចុះពីរថ បំណែករថនោះក៏ត្រឡប់ក្លាយទៅជាកំណាត់ឈើដូចដើមវិញ ។ ទាជ័ននឹងអារិនស្ថិតនៅត្រង់ទីជាខាងមុខប្រាសាទកែវ ។ ព្រះរាជធីតា គង់នៅក្បែរព្រះសីហបញ្ជរ ទ្រង់ព្រះពស្ត្រប៉ាក់ដោយខ្សែរមាសភ្លឺចិញ្ចាច ។ គ្រាន់តែក្រឡេកឃើញព្រះរាជបុត្រកាលណា ព្រះនាងកើតមានព្រះហឫទ័យប្រតិព័ទ្ធ ស្ទើរក្ស័យព្រះជន្មមួយរំពេច ។ ទ្រង់ប្រឈួនពុំសោយព្រះក្រយាស្ងោយ ហើយផ្ទុំល្ហិតល្ហៃ ។

ព្រះវរពជបិតារបស់ព្រះនាងទ្រង់ផ្ដាំមកវក្សាពេតាព្រះរាជធីតា តែឥតប្រយោជន៍ទាំងអស់ ។ លុះទីបំផុតមានយាយចាស់ម្នាក់ចូលមកក្រាបបង្គំទូលព្រះរាជាថា: បពិត្រព្រះសម្មតិទេពដ៏ទ្រង់នូវវិជ្ជាទុកាត! បើព្រះករុណាថ្លៃវិសេសមានព្រះរាជបំណងចង់ឲ្យព្រះរាជបុត្រីបានជាសះស្បើយនោះ សូមទ្រង់រកប្រើសមាសដែលចេះប្រៀងដ៏ពីរោះជាងសត្វបក្សីទាំងពួងក្នុងលោក ហើយសូមព្រះអង្គរក្សាប្រើសនោះទុកក្នុងព្រះបរមរាជវាំងតែបីថ្ងៃ នោះព្រះករុណានឹងបានឃើញព្រះរាជធីតា ជាសះស្បើយជាមិនខាន ។

ព្រះរាជាទ្រង់ព្រះបញ្ញាឲ្យរាជអាមាត្យប៉ាវគងទូងគេប្រាប់អស់បណ្ដាជនឲ្យជួយស្វែងរកប្រើសមាស ។ ក្នុងថ្ងៃទី ៣ អាវិនគោះកំណាត់ឈើបីដង កំណាត់ឈើនោះក៏ក្លាយជាប្រើសមាស រួចបញ្ចូលទាដ៏នទៅក្នុងពោះ ហើយដឹកយកទៅបញ្ឈរនៅពីខាងមុខប្រាសាទព្រះរាជា ។

ព្រះមហាក្សត្រិយ៍ លុះទតឃើញប្រើសមាស ស្ដេចយាងចុះមកដោយព្រះអង្គឯង ហើយសួរតើប្រើសមាសនេះ រគត្រូវការលក់ឬទេ? ។ អាវិនក្រាបទូលថា: សូមទ្រង់ព្រះមេត្តាប្រោស! មិនលក់ទេ បើជួលបាន ។ ព្រះរាជាទ្រង់សួរទៀតថា: យើងជួលឲ្យយើងបីថ្ងៃ តើឯងយកតម្លៃប៉ុន្មាន? ។ អាវិនក្រាបទូលថា: សូមព្រះករុណាថ្លៃវិសេសប្រោស! យកតម្លៃជាប្រាក់មាសមួយពាន់រៀល ។

លុះការនិយាយថ្លៃឈ្នួលស្រេចហើយក្តាម, ព្រះអង្គបង្គាប់ឲ្យគេនាំប្រើសមាសចូលក្នុងបន្ទប់ព្រះនាងកីឡាលីណា ហើយទ្រង់ស្តេចយាងទៅឯព្រះរាជដំណាក់វិញ ។

ប្រើសមាស កាលណាដឹងថាអាត្មានៅតែឯកឯងហើយ ក៏ស្រែកប្រៀងដោយសូរសៀងយ៉ាងស្រងេះស្រណោចអស្ចារ្យ សូម្បីដុំថ្មព្រឹក្សាលតាល់ល្មិ ក៏អត់ទ្រាំមិនចេញទឹកភ្នែកមិនបាន ។ ព្រះនាងកីឡាលីណាទ្រង់ផ្ទុំលក់, ចំណែកព្រះរាជបុត្របានស្តេចចេញពីពោះប្រើសមាស មកឧបថើបព្រះនាង ហើយត្រឡប់ចូលក្នុងពោះប្រើសមាសវិញ ។

លុះភ្លឺឡើង ព្រះនាងមានវាចាប្រាប់ស្រីគិលៀងទាំងឡាយថា ពីយប់មិញ ខ្ញុំយល់សប្តិឃើញមាណពម្នាក់រូបយ៉ាងឆើតចូលមកឧបថើបខ្លួនខ្ញុំ ។ ខណៈនោះ មានស្ត្រីម្នាក់យល់ដេងការណ៍ ក៏ប្រាប់ព្រះនាងថា: បពិត្រម្ចាស់ថៃ! កាលណាប្រើសមាសប្រៀងទៀត សូមម្ចាស់ធ្វើជាផ្ទុំលក់ ហើយកាលណាព្រះនាងដឹងថាមានអ្នកណាមកឧបថើប សូមព្រះនាងយកព្រះហស្តចាប់ឲ្យជាប់ ។

វេលារាត្រី ប្រើសតាំងប្រៀងទៀតដោយសំឡេងគួរឲ្យអាណោចអធ័មពេក ។ ព្រះរាជធីតាធ្វើជាផ្ទុំលក់ លុះព្រះរាជកុមារចេញមកឧបទៀត, ព្រះនាងចាប់ព្រះហស្តជាប់ ហើយមានព្រះបន្ទូលថា: ម្តងនេះ

ព្រះអង្គទៅណាលែងបានហើយ ទូលព្រះបង្គំតាំងយូរណាស់ហើយ ! គមក គូសង្សារផ្ដុំជាសុខជាមួយគ្នារហូតដល់ក្ស័ ។

ពេលថ្ងៃត្រង់ ព្រះរាជាស្ដេចយាងចូលមកជាមួយនឹងម្ចាស់ប្រើស ដែលត្រូវការត្រឡប់យកប្រើសវិញ ។ ចំណែកព្រះនាងទ្រង់កន្សែង ហូរទឹកព្រះនេត្រហាម ព្រោះសេចក្ដីអាល័យមិនបង់ឲ្យបែកចេញពីប្រើសនោះ ។ ខណៈនោះ អាវិនលួចខ្សឹបនឹងព្រះនាងថា: សូមព្រះនាងសុំលាព្រះវររាជបិតានឹងស្ដេចយាងជូនប្រើសទៅដល់ខាងក្រោយក្រុង. ហើយនៅទីនោះ មានព្រះរាជរថទឹមអស្សាសព្រោហ៍ទាំងដប់-ពីរ សម្រាប់នាំយើងទាំងអស់គ្នាទៅកាន់ព្រះរាជសីមានៃព្រះអង្គម្ចាស់ហាវហាន ដែលជាគូស្នេហារបស់ព្រះនាង ។

ព្រះរាជធីតាទ្រង់សុំព្រះចៅតាមពាក្យនៃអាវិន ព្រះមហាក្សត្រក៏ទ្រង់អនុញ្ញាតឲ្យមួយរំពេច ហើយគេនាំគ្នាដង្ហែប្រើសមាសជាអ៊ុកអធិកចេញរហូតដល់ទីបំផុតក្រុង ។ ក្សណនោះ អាវិនគោះប្រើសបីដង ប្រើសនោះក៏ក្លាយជាព្រះរាជរថទឹមដោយសេះក្រហមទាំងដប់ពីរ ។ រួបរកាន់ព្រះនាងដោយដៃម្ខាង ទាំដិនដោយដៃម្ខាងទៀត ហើយធក់លោតឡើងលើព្រះរាជរថ ។ តែមួយសន្ទុះ ជនទាំងបី យ៉ាតផុតបាត់ពីភ្នែកអ្នកទាំងពួង, មិនយូរប៉ុន្មាន ក៏បានទៅដល់ព្រះរាជវង្សានៃព្រះចៅជាព្រះវររាជបិតានៃទាជិនរាជកុមារ ។ -

កាលព្រះមហាក្សត្របានជ្រាបការវិលត្រឡប់នៃព្រះរាជបុត្រ ទ្រង់ស្តេចមកទទួលព្រមដោយសេនាយោធាជាច្រើន ហើយទ្រង់នាំព្រះរាជបុត្រយាងចូលព្រះបរមរាជវាំង ។ គ្រានោះ ព្រះរៅទ្រង់រៀបព្រះរាជអាពាហ៍ពិពាហ៍ជាឧឡារិក អស់កាលកំណត់បីថ្ងៃបីយប់ រួចអំពីកិច្ចនោះ ទ្រង់វេររាជសម្បត្តិប្រទានដល់ទាជិន ព្រះរាជបុត្រក៏ទទួលសោយរាជ្យស្នងព្រះអង្គ ។

ថ្ងៃមួយ ព្រះនាងកីឡាល័ណា ដែលគង់ត្រង់សីហបញ្ជរ បានទតឃើញឈ្មួញសំពាយម្នាក់ដើរលក់អាវទ្រនាប់ ។ ព្រះនាងប្រាប់ឲ្យគេហៅឈ្មួញនោះចូលមក ទ្រង់ទិញព្រះពស្ត្រទ្រនាប់ជាវិការៈអ្វី យ៉ាងឆ្ងាវជាងសរសៃពីងពាង ហើយក៏យកអាវនោះមកទ្រង់ភ្លាម ៗ មិនយូរប៉ុន្មាន ព្រះនាងប្រឈួនសន្លប់សន្លិន គេស្មានថាប្រហែលព្រះនាងនឹងពុំគង់ព្រះជន្មឡើយ ។

អាវិនដែលជាបុត្រនាងនាយពិសេសបានដឹងការណ៍ដូច្នោះ វេលាពាក់កណ្តាលអធ្រាត្រ ក៏លបលួចចូលក្នុងព្រះរាជបន្ទប់ដែលព្រះនាងកំពុងផ្ទំ យកទឹកក្អែកលលកមកព្រោះស្រប់ពីលើព្រះកាយព្រះនាង ហើយចេញទៅវិញបាត់ ៗ ប៉ុន្តែ រឿងនេះមិនបាត់ស្លាត់ឡើយ នាយឆ្មាំទ្វារទៅក្រាបទូលព្រះរាជាទាជិន ចោទប្រកាន់ថាអាវិនបានយកមន្តវិជ្ជាគាថាអ្វី ទៅស្រូតផ្លុំដាក់ពីលើព្រះសរីរកាយនៃព្រះអគ្គមហេសី ។

ព្រះចៅធាដិនទ្រង់ព្រះពិរោធ មានព្រះរាជឱង្ការបង្គាប់ឲ្យពេជ្ឈឃាតយកអាវិនជាកល្យាណមិត្រទៅកាត់ក្បាល ។ លុះបានទៅដល់កន្លែងធ្វើគត់ អាវិនក្រាបទូលព្រះរាជាថា : “បពិត្រព្រះចៅ! សូមព្រះជាម្ចាស់ជួយឲ្យទ្រង់មានព្រះជន្មាយុ ស្ថិតនៅអស់កាលជាយូរអង្វែង ។ ដោយសេចក្ដីស្នេហាជាភាតរភាព ដែលទូលព្រះបង្គំមានជានិច្ចចំពោះទ្រង់, ទូលព្រះបង្គំសូមអង្វរ សូមព្រះតេជះបារមី សូមទ្រង់ប្រជុំអស់នាម៉ឺនមុខមន្ត្រីធំៗ ក្នុងព្រះនគរ ព្រោះទូលព្រះបង្គំមានកិច្ចមួយយ៉ាងធំ ដែលទូលព្រះបង្គំត្រូវយកមកថ្លែងខានមិនបាន នៅចំពោះមុខនៃឥស្សរជនទាំងនោះ ។ រួចហើយ សូមទ្រង់សម្លាប់ទូលព្រះបង្គំចុះ” ។

ព្រះរាជាទ្រង់ប្រជុំអស់នាម៉ឺនមុខមន្ត្រីមួយរំពេចឥតបង្អង់, ព្រះអគ្គមហេសីកីឡាលីណាក៏ទ្រង់យាងមកដែរ ។ រួចព្រះរាជាឲ្យគេនាំអាវិនមក ហើយមានព្រះបន្ទូលថា : “ម្នាលអាចោរចិត្តក្បត់! ឯងចង់និយាយថាម៉េច ចូរឯងថាទៅ!”

ក្នុងឱកាសនោះ អាវិនផ្ដើមឡើងថាដូច្នេះ : “ក្នុងកាលដ៏កន្លងហើយ មានពេលមួយព្រះរាជបុត្រមួយព្រះអង្គ មានព្រះហឫទ័យប្រតិព័ទ្ធក្នុងរូបព្រះអង្គម្ចាស់ក្សត្រិយ៍មួយព្រះអង្គ នៅនានគរខាងនាយសមុទ្រ” ។ រួចរៀបរាប់រឿងហូរហែតាំងពីដើមដល់ចុងគឺ អំពីកាលទៅនៅសំណាក់ក្នុងផ្ទះយាយហិមវាត ទីង វាបានធ្វើដូចម្ដេចខ្លះក្នុងទីនោះ ។ ប៉ុន្តែកាលណា វា

និយាយដល់ត្រីកន្ធែង ដែលនាំគ្នាជិះច្រកគារលើកំណាត់ឈើ ហើយធ្ងន់ជ្រោះលោហធាតុ អាវិនក្លាយខ្លួនទៅជាថ្មពីជើងដល់ក្បាលជង្គង់ ។ ហើយក៏ចេះតែនិយាយតទៅទៀត, លុះដល់ត្រីកន្ធែងដែលកបញ្ចូលទាជិនទៅក្នុងពោះព្រើសមាស កក្លាយជាថ្មរហូតដល់ចង្កេះ . . . ។

ព្រះរាជាទីងព្រះរាជជាយា ដែលទ្រង់យល់ឃើញការស្លូតត្រង់របស់អាវិន ក៏ទ្រង់ព្រះកន្សែងទាំងពីរព្រះអង្គ ហើយអង្វរសុំឲ្យអាវិនឲ្យឈប់និយាយត្រឹមហ្នឹងចុះ ។ ប៉ុន្តែ អាវិនបន្តរឿងទៅទៀត, ហើយលុះកាលណាកបញ្ចប់រឿង អំពីធ្វើកិច្ចយ៉ាងដូចម្ដេច ដើម្បីស្រង់ជីវិតព្រះនាងកឡា-លីណា គឺកយកទឹកកែកសត្វលកទៅប្រោះព្រំលើព្រះកាយព្រះនាង, កក៏ក្លាយខ្លួនទៅជាថ្មតាំងពីជើងរហូតដល់ក្បាល ។

ព្រះរាជាទាជិន ទីងព្រះអគ្គមហេសីទ្រង់ព្រះកន្សែងស្ដាយអាវិនអស់ពីថ្ងៃពីយប់ ។ រួចក្សត្រទាំងពីរព្រះអង្គ ទ្រង់បង្គាប់ឲ្យគេយករូបថ្មនៃបុព្វការីបុគ្គលទៅដំកល់ទុកក្នុងព្រះរាជដំណាក់ ដើម្បីឲ្យទ្រង់អាចបានទតឃើញរាល់ថ្ងៃរាល់យប់ ។

លុះឆ្នាំទាំងឡាយកន្លងទៅ ព្រះរាជាប្រសូតបានព្រះរាជបុត្រមួយព្រះអង្គ ។

វេលាព្រឹកមួយ ព្រះចៅទាជិន ទ្រង់ថ្លែងប្រាប់ព្រះរាជាយាថា: ទ្រង់ស្ដេចសុបិនឃើញស្ត្រីម្នាក់ ស្លៀកសំពត់សដើរចូលមក, ស្ត្រីនោះ

និយាយប្រាប់ថា៖ «បើទ្រង់មានបំណងចង់ឲ្យអាវិនជាបងមានជីវិតរស់ឡើងវិញ សូមទ្រង់សម្លាប់ព្រះរាជបុត្រ ហើយយកឈាមទៅលាបដុំថ្ម» ។

ព្រះរាជទេពីឆ្លើយតបថា ព្រះនាងក៏ទ្រង់ព្រះសុបិនដូច្នោះដែរ ហើយមិនបាច់ប្រឹក្សាច្រើន, ក្សត្រទាំងពីរ (ស្វាមី ភរិយា) យកព្រះរាជបុត្រទៅសម្លាប់ភ្លាម ។ គ្រាន់តែឈាមព្រះរាជបុត្រទៅប៉ះ ដុំថ្មក៏ចាប់ញ័រមួយរំពេច រូបអាវិនក៏មានជីវិតឡើងវិញហើយនិយាយថា៖ អា៎! ទ្រង់ទូលព្រះបង្គំទទួលព្រះរាជទានដំណេកអីក៏លក់យូរម្ល៉េះ? ។ ព្រះរាជាឆ្លើយថា៖ មែនហើយបង! បងនឹងដេកតទៅទៀត ប្រសិនបើយើងកុំសម្លាប់ព្រះរាជបុត្រយកព្រះលោហិតមកប្រោះព្រំលើខ្លួនអ្នក ។

ខណៈនោះ អាវិនយកកាំបិតមកចោះម្រាមដៃ ហើយបន្ហូរឈាមទៅលើរូបសពព្រះរាជបុត្រៗ ក៏ត្រឡប់មានព្រះជន្មាយុឡើងវិញភ្លាម ។

ព្រះរាជាសប្បាយព្រះរាជហឫទ័យពេក ទ្រង់បង្គាប់ឲ្យអាណាប្រជានុរាស្ត្រ ក្នុងព្រះរាជរដ្ឋទាំងមូលឈប់ធ្វើការងារ ហើយលេងសើចតាមបំណងរៀងខ្លួនអស់ពេលដ៏យូរ ។

ចប់

## ការបណ្ដុះឆ័ស្វ័យ

## ព្រះមហាឧត្ដមវិជ្ជា ផលញាណោ ប៊ឹង-ប៉ម

*អាចារ្យសាលាបាលីរង វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង*

ឃុនបណ្ណាគារក្ស ប៊ូ-ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ អ្នកពិនិត្យកែ

(តមក)

---

៣ — វាចាពីរោះ សំដៅយកពាក្យស្រដីស្រទន់គួរត្រងត្រាប់ គួរក្រេបផឹក ទឹង ពីរោះដល់ត្រចៀក ជាសំដីចេញមកអំពីចិត្តដ៏បរិសុទ្ធ ដូចទឹកថ្លាស្អាត, ជាសំដីដឹកនាំឲ្យអ្នកស្ដាប់ត្រងត្រាប់ហើយ ធ្វើតាមបានមិនមានទោស អង្វរចិត្តអ្នកស្ដាប់ឲ្យឃើញថា គួរកាន់យកជាតួយ៉ាង ទឹង ជួយថែរក្សាលើកកំឡាំងចិត្តរបស់អ្នកស្ដាប់ឲ្យរីករាយ ប្រៀបដូចទឹកថ្លាដែលជួយកំឡាំងចិត្តរបស់អ្នកបរិភោគដូច្នោះ, **នេលា** ជាវាចាមិនខុស មិនមានទោស, **បេមនិយា** ជាវាចាគួរស្រឡាញ់ ព្រោះល្អ មិននាំឲ្យអ្នកស្ដាប់កើតសេចក្ដីក្រោធ គឺនាំឲ្យកើតសេចក្ដីស្រឡាញ់ចំពោះអ្នកនិយាយតែម្យ៉ាង, **ហទយង្គមា** ជាវាចាគាប់ចិត្តត្រូវចិត្តឬចាប់ចិត្ត មិនទើសចិត្ត ចូលទៅដក់នៅក្នុងចិត្តបានដោយងាយ, **កណ្ណសុខា** ជាវាចាពីរោះឬស្រួលដល់ត្រចៀកនឹងងាយស្ដាប់, **បោរី** ជាសំដីសុភាពទន់ភ្លន់, **ពហុជនកន្តា** ជាវាចានាំឲ្យរីករាយដល់ជនទាំងពួង, **ពហុជនមនាបា** ជាសំដីត្រូវចិត្តនៃមនុស្សច្រើនគ្នា ។

ពាក្យពីរោះ ឈ្មោះថាជាមហាស្នេហ៍និងជាមហានិយម ។ បើគេនិយាយច្រើនឡើង ក៏រឹតតែនាំឲ្យជាទីគោរពស្រឡាញ់របស់អ្នកស្តាប់ច្រើនឡើងដែរ ។ ព្រោះមនុស្សដទៃ កាលបានស្តាប់ហើយ រមែងតែគាប់ចិត្តជានិច្ច, សូម្បីបានស្តាប់ហើយ ក៏នៅតែចង់ស្តាប់ទៀត មិនចេះឆ្អែត មិនចេះខ្ពើម មិនធុញទ្រាន់ ព្រមទាំងចង់ធ្វើសមាគម រាប់អានជាមិត្តសំឡាញ់នឹងយើងទៀតផង ។ ក្រៅពីនេះ ពាក្យពីរោះ គង់បានជាប្រយោជន៍ដល់ដួងចិត្តទៀត ព្រោះធ្វើចិត្តរបស់ខ្លួនឯងឲ្យទន់ភ្លន់ស្រឡាញ់របៀប ចាត់ថាឲ្យគុណដល់ខ្លួននឹងឲ្យប្រយោជន៍ដល់អ្នកស្តាប់ ។ គង់ធម្មនីតិមានសំដែងគុណនៃពាក្យពីរោះ ទុកថា "យកឈ្នះសត្រូវបានដោយពាក្យទន់ភ្លន់, យកឈ្នះមនុស្សកោចយង់ឃ្នង់បានដោយពាក្យទន់ភ្លន់, វត្ថុមួយដែលមិនសម្រេចដោយពាក្យទន់ភ្លន់នោះគ្មានឡើយ, ត្រូវយកឈ្នះវត្ថុទាំងពួងបាន ដោយសារពាក្យទន់ភ្លន់ទាំងអស់" ។ ពិតមែន ព្រះពាយមិនដែលអាចនឹងបោកបក់គុម្ពស្មៅ ដែលទោរទន់ទាបទៅតាមឲ្យរលើងទៅបានឡើយ គឺបក់រំលំបានតែដើមឈើដែលធំខ្ពស់ ១ ចំណែកប៉ុណ្ណោះ, សូម្បីអ្នកមានឥទ្ធានុភាព ក៏មិនអាចរំលាយ មនុស្សដែលចេះទោនទន់ភ្លន់បានដែរ អាចរំលាយបានតែកំឡាំងរបស់អ្នកដែលមានពុទ្ធិខ្លាំងក្លាប៉ុណ្ណោះ ។

អាចយកឈ្នះ សត្រូវ នឹងជនកាច
បានដោយសារ អំណាច ពោលពាក្យ

ផ្អែមពីរោះ ទន់ភ្លន់ ឆ្ងាញ់ពីសា
នេះគម្រោ ពាក្យឆ្ងាញ់ ផ្ញាញ់មនុស្សកាច ។
ទាំងវត្ថុ សារពើ លើពសុធា
ដែលជនផង គប់គ្នា ប្រឹងប្រសាច
តែមិនអាច ឲ្យកើត ដោយអំណាច
គង់តែអាច កើតបាន ដោយពាក្យផ្អែម ។

សូម្បីការទទួលភ្ញៀវដែលទៅមករកគ្នា ក៏គង់មានការសន្ទនាប្រស្រ័យដោយពាក្យពីរោះចំពោះគ្នានឹងគ្នាជារបស់សំខាន់ដែរ ហើយសំខាន់ក្រៃលែងជាងការទទួលភ្ញៀវដោយអាហារ ដែលមានរសជាតិយ៉ាងប្រណីតបញ្ចូលប្លែកៗ ទាំងអស់ទៅទៀត ។ ព្រោះថាកាលបើម្ចាស់ផ្ទះឈ្លាសវៃចេះនិយាយប្រស្រ័យពីរោះផ្អែមល្ហែមហើយ រមែងបានឈ្មោះថាជាអ្នកនាំយករសដ៏ឆ្ងាញ់ក្រៃលែងជាងរសដទៃៗ មកឲ្យភ្ញៀវ ។ ដ្បិតរសនៃវាចា ដែលផ្អែមពីរោះនេះ ជាទីដក់ជាប់នៅក្នុងចិត្តរបស់អ្នកស្ដាប់ ធ្វើឲ្យអ្នកស្ដាប់កើតសេចក្ដីរីករាយសប្បាយក្រៃលែងជាងរបស់គ្រប់យ៉ាង ដែលយើងអាចដឹងបានដោយត្រចៀក ទាំងបានឈ្មោះថាជាគ្រឿងចងក្រៀកចិត្តរបស់អ្នកស្ដាប់ទុកដោយកុសលោបាយផង ។ គឺបើជាអ្នកធំក៏នឹងចងមេត្រីឲ្យកើតឡើងក្នុងរវាងអ្នកតូចបានយ៉ាងល្អ ទាំងចងភ្ជាប់នូវសេចក្ដីគោរពកោតក្រែងរបស់អ្នកតូចទុកបានផង ប្រសើរជាង

ការបង្ខំពន្ធទុកដោយអំណាច ឬការគ្រប់គ្រងយ៉ាងឯទៀតទាំងអស់ ។ បើជាអ្នកតូច ក៏នឹងបានជាទីករុណាប្រណីរបស់អ្នកធំ ទាំងបានអ្នកធំជាទីពឹងឧបត្ថម្ភគាំទ្រខ្លួនឲ្យចំរើនរុងរឿង ។ បើជាអ្នកជំនួញ ក៏នឹងមានអ្នកចូលទិញច្រើន ។

បណ្ឌិតអ្នកមានប្រាជ្ញាស្គាល់ហេតុផល រមែងកាន់យកថាការប្រស្រ័យពីរោះ ជានាទីដ៏សំខាន់របស់អ្នកម្ចាស់ផ្ទះ ។ ភ្ញៀវដែលមកកាន់ផ្ទះ ទោះមកដោយល្អ ឬមកដោយអាក្រក់ ក៏មិនជាសំខាន់ឡើយ ។ ព្រះបាទវេស្សន្តរ ទ្រង់ត្រាស់ប្រស្រ័យនឹងព្រាហ្មណ៍ជូជកដែលមកសូមព្រះរាជបុត្រព្រះរាជធីតាទាំងពីរ ធ្វើឲ្យតាជីកើតសេចក្ដីរីករាយដោយព្រះសូរសៀងពីរោះ ដូចយ៉ាងអញ្ជើញតាជីឲ្យលាងជើង ឲ្យចូលទៅក្នុងអាស្រម ឲ្យបរិភោគមើមឈើផ្លែឈើ នឹងឲ្យបរិភោគទឹកថ្លាត្រជាក់តាមគាប់ចិត្តជាដើម ។ នោះក៏ព្រោះព្រះអង្គទ្រង់កាន់យកការបរបាពីរោះ ថាជានាទីរបស់ព្រះអង្គ មិនបានរង្កៀសថា ជូជកជាយាចកថោកទាបឡើយ ។ នេះបាត់ថាជាតួយ៉ាងដ៏ប្រសើរនៃការប្រស្រ័យដ៏ពីរោះ ។

ពិតមែន ការទទួលប្រស្រ័យរាក់ទាក់ចំពោះគ្នានឹងគ្នា រមែងជាឧបាយប្រដាប់តុបតែងស្ព្រោះព្រំទឹកចិត្តគ្នាឲ្យតាំងនៅក្នុងមិត្តធម៌ ចំរើនមេត្រីចិត្តមិត្តភាពឲ្យជិតស្និទ្ធខ្ជាប់ខ្ជួនមាំមួនក្រៃលែងឡើង ។ តែបើមិនឈ្លាសក្នុងការទទួលភ្ញៀវ ដែលមកដល់ផ្ទះរបស់ខ្លួនដោយពាក្យជាដើមទេ ក៏

នឹងត្រឡប់ឲ្យទោសដល់ខ្លួនឯងវិញ ។ មើលចុះ! ពួកសាក្យរាជមិនឈ្លាសក្នុងការទទួលវិឌូឌភកុមារដែលជាព្រះរាជឱរសនៃព្រះបាទបសេនទិកោសល ទើបក្លាយទៅជាសាហេតុ នាំឲ្យព្រះរាជកុមារទ្រង់ព្រាបថា គេមើលងាយព្រះអង្គ ហើយក៏ទ្រង់ក្រោធចំពោះពួកសាក្យរាជ ។ លុះទ្រង់បានគ្រងរាជ្យហើយ ក៏លើកកងទ័ពទៅកំទេចសក្កជនបទឲ្យតាំងនៅក្នុងព្រះរាជអំណាច ។ នេះជាផលនៃវាចាដែលអ្នកពោលមិនឈ្លាសវៃ ចាត់ថាជាពិសនាំឲ្យកើតទោសក្នុងកាលដែលនិយាយចប់ ។

ដូច្នេះ លោក-អ្នក ប្រុស-ស្រីទាំងឡាយ ចូរអប់មាត់របស់លោក-អ្នកឲ្យក្រអូបប្រហើរដោយវាចាដ៏ពីរោះចុះ កុំបណ្ដោយឲ្យមាត់មានក្លិនស្អុយដោយសំដីអាក្រក់ឡើយ គឺកុំពោលពាក្យសំដីអាក្រក់ ចាក់រុកសឹកសៀត ឬសំដីណាដែលជាហេតុនាំឲ្យអ្នកដទៃក្ដៅចិត្ត ឈឺចិត្ត តូចចិត្ត ឬក្ដៅក្រហាយតបមកលោកវិញ ។ សំដីអាក្រក់គ្មាននរណាចូលចិត្តទេ ។ បើលោកបណ្ដោយវាចាបែបនោះឲ្យចេញមកក្រៅ ឈ្មោះថា ស្ដោះទឹកមាត់ដាក់អាកាស ។ បើស្ដោះលេងញយៗ ប្រយ័ត្នទឹកមាត់នោះធ្លាក់មកលើសីសៈខ្លួនវិញ ។ ព្រោះការធ្វើបែបនោះចូលក្នុងគតិថា "បើលោក-អ្នកវាល់របស់ឲ្យគេដោយនាឡិឯណា គេនឹងវាល់សងមកលោក-អ្នកដោយនាឡិនោះវិញ" ។ ហេតុនេះ ត្រូវតាំងស្មារតីថា នឹងមិនពោលពាក្យគ្រោតគ្រាតពាក្យចាក់រុក ពាក្យសឹកសៀត បំបែកនរណាពីនរណាឡើយ ។

បើលោក-អ្នកមិនពេញចិត្តចំពោះឋានៈខ្លួន ហើយបណ្តោយឲ្យមាត់និយាយពាក្យគ្រោតគ្រាតបាក់រុកអ្នកដទៃវិញ ក្រៅអំពីការស្តោះទឹកមាត់ដាក់អាកាសហើយ ក៏គង់បានឈ្មោះថា កែះឬដោយក្រចក, ទំពាស៊ីដុំដែកដោយធ្មេញ ឬព្យាយាមលេបដុំភ្លើងដែលឆេះក្រហមរន្ទាល ៗ ត្រូវកុំកែះឬដោយក្រចក កុំទំពាស៊ីដុំដែកដោយធ្មេញ ឬកុំព្យាយាមលេបដុំភ្លើងឡើយ ព្រោះនាំឲ្យរបេក្រចក បាក់ធ្មេញ រលាកមាត់, រលាកបំពង់ក ៗ ចូរដាស់តឿនខ្លួនឲ្យទាល់តែចិត្តកើតហិរិឱត្តប្បៈលែងហ៊ានពោលពាក្យអាក្រក់ដូច្នោះតទៅទៀត ៗ បើលោក-អ្នកកែនិស្ស័យវាចាអាក្រក់ឲ្យត្រឡប់ជាល្អបានហើយ, និស្ស័យអាក្រក់បែបដទៃ ៗ ទៀត ដូចយ៉ាងនិស្ស័យបរិភោគគ្រឿងស្រវឹង និស្ស័យចូលចិត្តលេងល្បែងភ្នាល់ និស្ស័យខ្ជាច និស្ស័យខ្ជិល និស្ស័យមិនទៀងត្រង់តាមពេលវេលា ឬសូម្បីតែនិស្ស័យលូតលូង ក៏លោកអាចកែឲ្យសម្រេចឲ្យល្អបានតាមទំនងនេះទាំងអស់ ៗ

កាលបើមាន កៀវចូលមក រកអាត្មា
ចូរចរចា តែពាក្យផ្អែម យ៉ាងស្រស់ស្រាយ
ការរាប់អាន បានយ៉ាងនេះ ឆ្ងាញ់មាល្បាយ
លើសលុបអស់ រសទាំងឡាយ គង់ផែនភព ៗ
ការចរចា ពាក្យបាក់រុក ទុកដូចកាប់

អារត្រចៀក ឲ្យឈឺចាប់ គ្មានបេះឈប់
តាំងកៀនផង គង់ហ្មងចិត្ត គិតលែងគប់
ឬរកពេល ដែលនឹងចប់ តបវិញណា ៗ
ក្តីទុក្ខទោស កើតព្រោះមាត់ មានសន្ធឹក
សូមរពុក នឹកមើលចុះ មិនខុសថា
គង់ឃើញថ្មី ថាសំដី ឆ្ងាញ់ពីសា
នាំចិន្តា ជនអ្នកស្តាប់ ឲ្យចាប់ចិត្ត ៗ
កាលលោកប្រាប ភាពសំដី ផ្អែមនឹងជូរ
ថាជាគូ មានទោសគុណ ខុសគ្នាពិត
គួរនិយាយ តែពាក្យផ្អែម ឲ្យទាល់ស្និទ្ធ
កុំជាប់ចិត្ត នឹងពាក្យជូរ ជាគ្រឿយ ៗ

(មានត)

# រឿងសាមកុក

## កណ្ឌទី ១០

## ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នកវាងវៃឆ្លាសបើបានអាន
> នឹងបេះឧបាយកលបំណាន
> ទាំងបានសន្តានស្នេហាជាតិ ។

ទៀតតបថា អ្នកទឹងទៅនៅទីដទៃនោះ សេចក្ដីគរហានិន្ទាទឹងមានដល់យើង, ដែលគៀរហ៊ុយនៅចិត្តពាលស្រាលសេចក្ដី បានស្ដីទ្រគោះបោះបោកឲ្យអ្នកនោះ ថ្ងៃក្រោយ ខ្ញុំនឹងនាំខ្លួនទៅសុំខមាទោសទឹងអ្នក បើអ្នកមិនចូលចិត្តនៅក្នុងទីនេះក៏ចូលទៅនៅឯស្រុកសៀវផាយចុះ ព្រោះស្រុកនោះក៏ជាទីស្រុកតូចឡើងដល់ស្រុកនេះ, បើខ្វះខាតស្បៀងអាហារ រ.ប ណា សូមយើងផ្ញើបញ្ជូនទៅឲ្យ ។

លីប៉ោបានស្ដាប់ក៏មានអំណរសោទរតំនាប់ទៀតហើយ ក៏នាំគ្រប់គ្រងទឹងសេនាទាហានទៅនៅស្រុកសៀវផាយ ។

# កណ្ឌទី ១១

ចាប់តាំងពីចូឆូធ្វើសំបុត្រទៅក្រាបទូលព្រះចៅហៀនតេថា ខ្លួនបានបង្ក្រាបសឹកសត្រូវនៅអាណាខេត្រទិសបូពាំជ្រះស្រឡះហើយ រៀងរហូតដល់ព្រះចៅហៀនតេ ស្ដេចយាងចូលទៅក្នុងក្រុងឡុកអៀង ហើយទតឃើញព្រះរាជតំណាក់ក្នុងព្រះរាជវាំងត្រូវភ្លើងឆេះអស់ ទើបទ្រង់សោកស្ដាយ ។

---

ឯចូឆូ កាលច្បាំងបានអាណាខេត្រប៉ែកខាងបូពាំទិស មកជាចំណុះខ្លួនវិញហើយ ក៏បកសំបុត្រចូលទៅក្រាបទូលព្រះចៅហៀនតេ ជាសេចក្ដីថា "ទូលព្រះបង្គំជាខ្ញុំចូឆូ បានប្រាបប្រាមសឹកសត្រូវទាំងពួកអាចោរកំណាច ក្នុងអាណាខេត្របូពាំទិស រាបទាបអស់ហើយ" ។ សំបុត្របកនោះ លីឈុយគុយគីទទួលហើយ ក៏ព្រងើយកន្តើយមិនបានយកទៅថ្វាយសោះ គិតតែងតបអែបព្រះតម្រាស់បញ្ជូនទៅឲ្យចូឆូវិញថា ចូឆូមានសេចក្ដីគាប់ប្រសើរ ធ្វើរាជការចំរើនប្រយោជន៍ សូមទ្រង់ឲ្យឡើងទីជា "កៀនតិកបុងកុះ" ប្រែថា "ឧកញ៉ាចំរើនអាយុ" ។ ខណៈនោះ លីឈុយនៅក្នុងស្រុកក្រុងក៏តាំងខ្លួនជាធំ សម្រេចអាណាចក្រខាងទាហាន, គុយគីជាធំសម្រេចរាជការខាងភ្នាក់ងាររដ្ឋបាល ។ អ្នកទាំង ២ នេះបណ្ដាលឲ្យកំរើកចិត្ត ប្រព្រឹត្តចាត់ចែងការរាជការជាកម្មសិទ្ធិលើខ្លួនទាំងអស់ មិនមានកោតខ្លាចព្រះចៅហៀនតេនឹងបណ្ដានាហ្មឺនទាំងពួងសោះ, រាជការផែនដីក៏វិប្បរិតប្រែប្រួលដូចកាលត្រាកាំងកុះ ។

ខណៈនោះ អៀវពីវទឹងដូហ៊ុជានាហ៊ុនធំក្នុងស្រុកក្រុង ឃើញលីឈុយគុយគីតាំងខ្លួនជាធំ ហើយកាត់តែងការរាជការជាទុច្ចរិតប្រព្រឹត្តអាក្រក់ ក៏យកសេចក្ដីនេះលបក្រាបទូលព្រះចៅហៀនតេ ហើយថា ទូលព្រះបង្គំជាខ្ញុំយល់ឃើញចូចូជាមន្ត្រីមានសតិបញ្ញាក្លាហាន មានសេនាទាហានប្រហែល ៣០ ម៉ឺន ពួកសេនាខ្លាំងពូកែជាច្រើន ឥឡូវនេះបានជាធំខាងអាណាខែត្របូព៌ាទិសទាំងអស់ បើបានចូចូនោះមកធ្វើរាជការផ្ទាល់ព្រះអង្គក្នុងស្រុកក្រុង នឹងបានបង្ក្រាបពួកសត្រូវរាជសម្បត្តិចេញបាន ទីព្រះរាជឋាននឹងអាណាខែត្រក្នុងក្រៅ ក៏នឹងនៅជាសុខក្សេមក្សាន្តទៅ ។ ព្រះចៅហៀនតេទ្រង់ព្រះសណ្ដាប់ដូច្នោះ ក៏ទោមនស្សក្នុងព្រះទ័យទ្រង់ព្រះកន្សែងសោកាអាណិតព្រះអង្គ ទើបទ្រង់ត្រាស់តបថា សព្វថ្ងៃនេះយើងមានតែសេចក្ដីព្រួយ ក្នុងចិត្តទុកជានិច្ចកាលនឹងបណ្ដាលហាមាត់និយាយមិនបាន បើមានអ្នកឯណាមានដំរេះប្រាជ្ញាចេះគិតរំលាងបច្ចាមិត្ររាជសត្រូវនេះបាន ទើបយើងនឹងមានសេចក្ដីសប្បាយ ។

អៀវពីវទូលថា ទូលព្រះបង្គំជាខ្ញុំនឹងគិតកលឧបាយឲ្យលីឈុយនឹងគុយគីកើតទាស់ទែង ធ្វើចម្បាំងកាប់សម្លាប់គ្នាឲ្យបាន រួចសុំឲ្យមានព្រះតម្រាស់ទៅហៅចូចូឲ្យលើកទ័ពចូលមក ទើបនឹងបានរំលាងបំពាក់ពួកអាកំណាចឲ្យអស់ចេញ ព្រះអង្គក៏នឹងបានសេចក្ដីសុខវិញពុំខាន ។

ព្រះចៅហៀនគេត្រាស់សួរអៀវពៅថា កលឧបាយដែលគិតនោះតើប្រការម្ដេច ? ។ អៀវពៅក្រាបទូលថា ភរិយាគុយគីនោះជាស្រីប្រច័ណ្ឌប្ដីណាស់ ទូលព្រះបង្គំជាខ្ញុំនឹងប្រើស្រីម្នាក់ឲ្យទៅញុះញង់ភរិយាគុយគី ឲ្យកើតសង្គ្រោះសង្ស័យនឹងគ្នាឡើង ។ ព្រះចៅហៀនគេទ្រង់ព្រះសណ្ដាប់ ក៏ជូរស្រួលក្នុងព្រះទ័យមានសេចក្ដីត្រេកអរ ទើបទ្រង់ព្រះសុភអក្សរដែលនឹងឲ្យហៅចូចូនោះ ប្រគល់ទៅឲ្យអៀវពៅរក្សាទុក ហើយត្រាស់ផ្ដាំថា បើកើតហេតុឡើងកាលណា អ្នកត្រូវចាត់បំរើឲ្យនាំសំបុត្រនេះទៅឲ្យចូចូវេលានោះ ។

អៀវពៅទទួលសុភអក្សរហើយក្រាបបង្គំលាថយមកវិញ នាំជូហ៊ីត្រឡប់ទៅផ្ទះហើយនិយាយពន្យល់ភរិយារបស់ខ្លួនជាមុន ហើយទើបប្រើឲ្យទៅសួរភរិយាគុយគី ។ ភរិយាអៀវពៅលុះឡើងទៅលើផ្ទះក៏គំនាប់តាមទំនៀមទម្លាប់ហើយនិយាយថា នាងខ្ញុំឮកិត្តិសព្ទថា ស្វាមីរបស់អ្នកបានទៅលបស្រ្គសហាយស្មន់នឹងប្រពន្ធលីឈុយ បើរឿងនេះដឹងដល់លីឈុយហើយ លីឈុយគង់នឹងធ្វើអន្តរាយដល់គុយគីជាស្វាមីអ្នកមិនខាន អ្នកត្រូវគិតអានហាមប្រាប់ស្វាមីកុំឲ្យទៅប្រព្រឹត្តដូច្នោះទៀតដែលខ្ញុំអាចកាត់ចិត្តចូលមកជំរាបដំណឹងអ្នកដូច្នេះ ព្រោះមានសេចក្ដីអាណិតអ្នកណាស់ ។ ភរិយាគុយគីបានឮដូច្នោះក៏ភ័យលោះព្រលឹងហើយនឹកទឹងក្នុងចិត្តខ្លាំងណាស់ ឆ្លើយថា ប្ដីខ្ញុំតែងទៅរកលីឈុយជាញឹក

ញយណាស់  ចួនកាលនៅដេកឯផ្ទះគេក៏មាន  ខ្ញុំគិតថាកៀនក៏ក្តីអ្នករាជ-ការជាមួយគ្នា;  ដែលប្តីខ្ញុំទៅលបបរទោរការទឹងករិយាលីឈុយនោះ  ខ្ញុំឥតដឹងសោះ  អ្នកមានចិត្តសប្បុរសមកប្រាប់ខ្ញុំៗអរគុណច្រើន  អំណើះពីថ្ងៃនេះទៅខ្ញុំទឹងត្រូវហាមមិនឲ្យប្តីខ្ញុំទៅផ្ទះលីឈុយទៀត  ។  ករិយាអៀវពីកើលទៅផ្ទះខ្លួន  ។

លុះកន្លងមកថ្ងៃ ១ លីឈុយឲ្យបំរើទៅអញ្ជើញគុយគីមកបរិភោគអាហារ ។ ករិយាគុយគីដឹងក៏អង្វរឃាត់ប្តីថា  ដែលអ្នកទឹងទៅសេពសុករបស់លីឈុយនោះ  អ្នកទឹងលីឈុយមិនមែនចំណុះគ្នា  សុទ្ធតែប្រកាន់ខ្លួនជាធំរៀងខ្លួន  ខ្ញុំក្រែងអ្នកសេពសុកស្រវឹងមិនដឹងខ្លួន  ហើយលីឈុយទឹងលបដាក់ថ្នាំពុលឲ្យអ្នកផឹក  អ្នកទឹងដល់សេចក្តីស្លាប់អសារឥតការខ្លួនខ្ញុំជាស្រីទឹងបែរមុខទៅរកអ្នកឯណាបាន  ។  គុយគីបានស្តាប់ករិយាឃាត់ក៏មិនបានទៅ  ។  លីឈុយអង្គុយចាំបាយទាល់តែថ្ងៃរសៀលមិនឃើញគុយគីមក  ទើបប្រើបំរើឲ្យយកម្ហូបចំណី ១ តុទៅជូនគុយគីដល់ផ្ទះ  ។  គុយគីនៅដេកមិនទាន់ភ្ញាក់  ករិយាក៏ក្រោកម្នីម្នាទៅទទួលសម្រាប់នេះទុក ហើយលបយកថ្នាំពុលដាក់ក្នុងចានម្ហូបនោះគ្រប់ចាន ។ លុះគុយគីភ្ញាក់ឡើង  មនុស្សបំរើក្នុងផ្ទះលើកម្ហូបនោះទៅឲ្យគុយគីបរិភោគដំរាបថា  តុនេះលីឈុយឲ្យបំរើយកមកជូន  ។  ករិយាក៏ម្នីម្នាស្ទុះទៅហាមឃាត់មិនឲ្យប្តីបរិភោគហើយថា “ចំណីនេះអ្នកកុំអាលពិសា  ចូរ

ពិសោធមើលសិន" ថាហើយក៏ចាក់ឲ្យសុនខស៊ី ។ សុនខនោះក៏ស្លាប់មួយរំពេច, គុយគីឃើញដូច្នោះក៏រឹតតែសង្ស័យ ។

មានកាល ១ ថ្ងៃ លីឈុយចេញអំពីទីគាល់ហើយអញ្ជើញគុយគីទៅប្រឹក្សាការរាជការឯផ្ទះ រួចលីឈុយអញ្ជើញគុយគីឲ្យបរិភោគអាហារ ។ គុយគីក្រោកឡើងដើម ទើបបរិភោគអាហារនោះរួចក៏លាទៅ លុះទៅដល់ផ្ទះក៏បណ្ដាលឲ្យឈឺក្នុងពោះ ។ ភរិយាសួរថា អ្នកចេញពីគាល់បានទៅឯណាខ្លះ? ។ គុយគីថា បានទៅប្រឹក្សាការរាជការឯផ្ទះលីឈុយហើយគេរៀបបាយទឹកឲ្យបរិភោគ ។ ភរិយាធ្វើជាតក់ស្លុតហើយថា "ខ្ញុំឃើញច្បាស់មួងហើយ ម្ដេចខំទៅពិសាបាយទឹករបស់គេទៀត គេមិនដាក់ថ្នាំបំពុលទេឬ?" ថាហើយក៏យកអាចម៍មករំលាយនឹងទឹកហើយឲ្យគុយគីផឹកចូលទៅ គុយគីក៏ក្អួតបង្ហោរចេញមកអស់ ពោះនោះក៏បាត់ឈឺទៅវិញ ។

គុយគីក៏ខឹងខ្ទឹងនឹងលីឈុយថា "យើងបង់កំឡាំងដែលបានរួមគំនិតគិតធ្វើការធំជាមួយគ្នាមកនោះសោះ ព្រោះលីឈុយនោះ មិនមែនត្រង់សុចរិតគិតប្រទូសរ៉ាយយើងវិញដូច្នោះ ត្រូវតែយើងគិតសម្លាប់វាចេញឲ្យបាន" គិតហើយក៏រៀបចាត់ចែងសេនាទាហាន នឹងលើកទៅព័ទ្ធចាប់លីឈុយក្នុងផ្ទះ ។

ពេលនោះមានមនុស្សលបទៅប្រាប់លីឈុយថា គុយគីនឹងលើកទាហានមកធ្វើអន្តរាយឥឡូវហើយ ។ លីឈុយភ្ញាក់ខ្លួនហើយថា "យើង

មិនមានទោសអ្វីនឹងគុយគីសោះ ហេតុម្តេចគុយគីអង់អាចគិតទឹងមកប្រ-ទូសរ៉ាយយើងដូច្នេះ រឿងនេះយើងទឹងនៅស្ងៀមក៏ពុំបាន ត្រូវតែលើកទាហានទៅចាប់គុយគីសម្លាប់ជាមុន" គិតហើយក៏ប្រមូលផ្តុំទាហានលើកទៅប្រទះទ័ពគុយគី នៅក្បែរកំផែងស្រុក ក៏តាំងតយុទ្ធគ្នាទៅវិញទៅមកជាចលាចល ៗ ពលទាហានទាំងសងខាង ក៏ឆក់ដណ្តើមយកទ្រព្យរបស់អស់បណ្តារាស្ត្រគ្រប់ផ្ទះ ៗ

ឯលីឈុយក៏ប្រើលីសៀមជាក្មួយ លើកទាហានទៅឡោមព័ទ្ធវាំងទុក ៗ លីសៀមទើបប្រើកាសៀងឲ្យយកព្រះរាជរថ ២ ចេញមក ហើយអញ្ជើញព្រះចៅហៀនតេ ឲ្យឡើងគង់លើព្រះរាជរថ ១ ឲ្យព្រះនាងហុកហៅដែលជាព្រះអគ្គមហេសីគង់ព្រះរាជរថ ១ ហើយផ្ទាប់ពីក្រោយ ឲ្យពួកព្រះស្នំនឹងក្រុមខន្ទីបរចេញចាកព្រះរាជវាំង តាមទ្វារព្រះស្នំចេញទៅ ៗ ឯលីឈុយនឹងគុយគីក៏តាំងតែច្បាំងគ្នាជាចលាចលរាល់ថ្ងៃ ៗ កាលព្រះរាជរថ បរចេញចាកព្រះរាជវាំងទៅនោះ គុយគីក៏ក្រឡេកឃើញលីសៀមនឹងកាសៀងលើកទាហាននាំស្តេចព្រះចៅហៀនតេ នឹងព្រះអគ្គមហេសីនូវស្រីព្រះស្នំចេញទៅដូច្នោះ ក៏បង្គាប់សេនាទាហានឲ្យបាញ់ធ្នូរណ្តំពីក្រោយ ព្រួញរត់បណ្តោយទៅត្រូវពលទាហាននឹងស្រីស្នំស្លាប់អស់ជាច្រើន ៗ លីឈុយដឹងដូច្នោះ ក៏លើកទាហានស្រូតទៅស្ទាក់កាប់តាក់ទាហានគុយគីៗ តទល់ពុំឈ្នះ ក៏ប្រាស់ទ័ពលើកត្រឡប់មក

ក្រោយ ៗ លីឈុយក៏នាំព្រះចៅហៀនតេនឹងព្រះមហេសីស្រីព្រះស្នំ ទៅតាំងជំរំនៅក្រៅក្រុង ១ អន្លើ ៗ

ឯគុយគីក៏លើកទាហានចូលទៅក្នុងព្រះរាជវាំង រើយកទ្រព្យរបស់ក្នុងផ្ទៃព្រះឃ្លាំង ហើយចាប់ពួកព្រះស្នំដែលលាក់ខ្លួនក្នុងព្រះរាជវាំងនោះមកទុក រួចយកភ្លើងដុតព្រះរាជវាំងឆេះវិនាសអស់ ៗ លុះពេលព្រឹកគុយគីដឹងថា លីឈុយនាំព្រះចៅហៀនតេ ទៅតាំងជំរំនៅក្រៅទីក្រុង ក៏លើកទាហានទៅតាមប្រទះទ័ពលីឈុយ ហើយប្រយុទ្ធគ្នាដណ្តើមយកព្រះចៅហៀនតេ ៗ លីឈុយក៏ដេញទាហានចូលតយុទ្ធនឹងកងទ័ពគុយគី ៗ តទល់ពុំឈ្នះ ក៏ប្រាសត្រឡប់ទ័ពទៅ ៗ

លីឈុយឃើញកងទ័ពគុយគីថយទៅវិញ ក៏អញ្ជើញព្រះចៅហៀនតេនឹងព្រះអគ្គមហេសីនឹងស្រីស្នំ ទៅប្រថាប់គង់ឯទីក្រុងដែលតាំងគុះកសាង ហើយបង្គាប់លីសៀមឲ្យនៅមើលត្រួតត្រារក្សាព្រះអង្គ កុំឲ្យអ្នកឯណាយកចំណីត្រីសាច់អ្វីៗ ទៅឲ្យខន្ទីឬពួកស្រីស្នំបរិភោគឡើយ ៗ ព្រះចៅហៀនតេឃើញរាជការទាំងស្រីប្រុស អត់ឃ្លានគ្មានអាហារចំណីនឹងបរិភោគដូច្នោះ ក៏ទ្រង់មានសេចក្តីទោមនស្សអាណិតអាសូរណាស់ ត្រាស់ប្រើខន្ទីឲ្យទៅសុំបាយនឹងសាច់គោពីលីឈុយៗ ខឹងនឹងព្រះចៅហៀនតេថា បានសោយគ្រប់វេលាហើយ ហេតុម្តេចបានជាឲ្យទៅសុំអាហារ នឹងឲ្យអ្នកឯណាស៊ីទៀត ៗ (មានត)

# ព្រះរាជពង្សាវតារប្រទេសកម្ពុជា

## ភាគទី ២

## សម័យនគរធំ

### ឧកញ៉ាទេពពិទូរ ឈឹម-ក្រសេម រៀបរៀង

(តមក)

## ព្រះបាទស្រីន្ទ្រវរ្ម័ន ទី ២

ព. ស. ១៨៣៨—១៨៥០, គ. ស. ១២៩៥—១៣០៧

កាលព្រះបាទជ័យវរ្ម័នទី ៨ សោយទិវង្គតហើយ ព្រះស្រីន្ទ្រវរ្ម័ន បានទទួលគ្រងរាជសម្បត្តិតមក មានព្រះបរមនាមថា "ព្រះបាទស្រីន្ទ្រវរ្ម័ន" រាប់ជាទី ២ គង់នៅក្រុងស្រីយសោធរបុរៈ ។ ព្រះមហាក្សត្រអង្គនេះ ជារាជឱរសនៃព្រះនាងស្រីន្ទ្រភូបេស្វរចូឡា ហើយត្រូវជាព្រះរាជនត្តានៃព្រះបាទជ័យវរ្ម័នទី ៨ ទ្រង់មានព្រះអគ្គមហេសីព្រះនាមដូចម្តេចមិនប្រាកដ តែព្រះអគ្គមហេសីនោះ ជាព្រះរាជធីតារបស់ព្រះបាទជ័យវរ្ម័នទី ៨ ទ្រង់មានព្រះរាជឱរស ១ អង្គព្រះនាមស្រីន្ទ្រជ័យវរ្ម័ន មានព្រះរាជធីតា ១ អង្គព្រះនាមដូចម្តេចមិនប្រាកដ ប្រាកដតែថាព្រះនាងនោះជាទីប្រោសប្រាណរបស់ព្រះរាជបិតាយ៉ាងក្រៃលែង ក្នុងឆ្នាំដែលទ្រង់ឡើងសោយរាជ្យ ព្រះរាជធីតានោះក៏មានព្រះរាជស្វាមីហើយ, ក្រោយមក ព្រះជាមាតរកូនប្រសាប្រុសនេះត្រូវទោសយ៉ាងធ្ងន់ ព្រោះឲ្យលួចយកព្រះខ័នមាសរបស់ព្រះរាជបិតាក្មេក ។

ការផែនដី.– ក្នុងរដ្ឋកាលនេះ មិនប្រាកដថាបានកសាងរបស់សំខាន់អ្វីទុកទេ ផែនដីខ្មែរភាគខាងលើ គឺខែត្រសុខោទ័យ នឹងខែត្រដទៃខ្លះទៀតដែលបានទៅក្នុងកណ្ដាប់ដៃជាតិថៃ តាំងពីក្នុងរដ្ឋកាលព្រះបាទជយវរ្ម័នទី ៨.ជាដើមមកនោះ ថៃក៏រឹតតែរុករានយកបានធំឡើងៗ ក្នុងរដ្ឋកាលនេះ ទ្រង់បានចាត់សេនាទាហានឲ្យទៅច្បាំងទប់ថៃដែរ តែឃើញដូចជាមិនសូវបានផល ។

ក្នុងឆ្នាំដែលព្រះបាទស្រីន្ទ្រវរ្ម័នសោយរាជ្យនោះ ខាងប្រទេសចិនមានស្ដេច ១ អង្គ ព្រះនាម យួនចេង បានឡើងសោយរាជ្យក្នុងឆ្នាំជាមួយគ្នានេះដែរ ប្រាកដព្រះកិត្តិយសជារាជាធិរាជ បានចាត់រាជទូតឲ្យមកកាន់ប្រទេសកម្ពុជា ។ ការមកនៃរាជទូតចិនគ្រានេះ ឃើញដូចជាមិនមែនមកសុំចងសម្ពន្ធមេត្រីភាពដូចក្នុងរដ្ឋកាលមុនៗទេ គ្រាន់តែប្រកាសថា ប្រទេសចិនជាមហាប្រទេស ក្សត្រិយ៍ដែលសោយរាជ្យជារាជាធិរាជ ហើយក៏ត្រឡប់វិញ ។

ក្នុងឆ្នាំជាមួយគ្នានេះ មានអ្នកប្រាជ្ញចិន ១ នាក់ ឈ្មោះ "ជាវ-តាក្វន" បានមកកាន់ប្រទេសកម្ពុជា សំណាក់នៅក្នុងដែនក្រុងស្រីយសោធរបុរ.ជាង ១ ឆ្នាំ ទើបត្រឡប់ទៅប្រទេសចិនវិញ ។ ក្នុងពេលដែលមកនៅក្នុងប្រទេសនេះ បានធ្វើសេចក្ដីកត់ហេតុផ្សេងៗរួមទាំង ៤០ រឿង ។ ក្នុងរឿងអំបាលនេះ មានរឿងខ្លះទាក់ទាមដោយព្រះរាជពង្សាវតារ រឿង

ខ្លះទាក់ទាមដោយទំនៀមទម្លាប់ ។ល។ នឹងស្រង់យកចំពោះតែរឿង ដែលទាក់ទាមដោយព្រះរាជពង្សាវតារ នឹងទំនៀមទម្លាប់ខ្លះមកសំដែង ក្នុងទីនេះ ដូចតទៅនេះ :—

និយាយអំពីភាពនិងលក្ខណៈ ព្រះបរមរាជវាំងស្រីយសោធរៈបុរៈ វាំងជាន់ក្នុង វាំងជាន់ក្រៅ យ៉ាងល្អិតល្អសព្វគ្រប់ ឃើញត្រូវតាមភាពដែលប្រាកដនៅក្នុងបច្ចុប្បន្ននេះឥតល្អៀង ថាប្រាសាទសិលាក្នុងព្រះបរមរាជវាំងនោះមានកំពូលសុទ្ធតែទឹកមាសប្រោលផ្ដៅ នឹងមានស្ពានមាសនៅក្នុងព្រះបរមរាជវាំងនោះផង(១) ។

ព្រះមហាក្សត្រិយ៍ព្រះបាទស្រីន្ទ្រវរ្ម័ន គង់នៅក្នុងព្រះបរមរាជវាំងជាន់ក្នុង គឺព្រះរាជនិវេសន៍តាំងនៅខាងលិចប្រាសាទវិមានអាកាសចម្ងាយ ១ លី ។ តាមធម្មតាព្រះមហាក្សត្រិយ៍ខ្មែរ ទ្រង់ព្រះពស្ត្រ (សំពត់) ដែលល្អជាបំផុត ព្រះពស្ត្រមួយៗ ដំឡៃ ២-៣ ដំឡឹងមាស, ព្រះសិរតែងប្រដាប់ដោយកម្រងផ្កាម្លិះជានិច្ច វៀរតែក្នុងពេលដែលត្រូវទ្រង់មកុដ, បាតព្រះហស្តនឹងបាតព្រះបាទតែងលាបដោយចុណ្ណក្រហម (Crème) (២) ពួកស្ត្រីអ្នកមានបណ្ដាស័ក្តិនៅក្នុងព្រះបរមរាជវាំង ក៏មានលាបចុណ្ណក្រហមនេះដែរ ។

---

១ ស្ពានមាសនេះ គឺស្ពានថ្ម ដែលឆ្លងទៅប្រាសាទហេមាទ្រី (បាពួន) ។ ២ ទំនៀមប្រើក្រែមនេះ កើតឡើងនៅឥណ្ឌៀជាដំបូង ហើយផ្សាយមកប្រទេសកម្ពុជានឹងប្រទេសចិន, ក្រោយអំពីនោះមក ទើបផ្សាយទៅប្រទេសអឺរ៉ុប ប្រើមកដល់សព្វថ្ងៃនេះ ។

ព្រះរាជវនិតាធំរបស់ព្រះមហាក្សត្រិយ៍មានចំនួន ៥ អង្គ គឺ អង្គទី ១ មានតំណែងយសជា «ព្រះអគ្គមហេសី» ឬហៅ «ព្រះរាជិនី» (reine) នៅប្របព្រះមហាក្សត្រិយ៍ជានិច្ច ។ បួនព្រះអង្គទៀត មានតំណែងយសជា «ព្រះរាជទេវី» ស្មើគ្នាទាំងអស់ នៅក្នុងប្រាសាទជាមួយនឹងព្រះមហាក្សត្រិយ៍ តែក្រលាព្រះបន្ទំផ្សេងគ្នា នៅតាមទិសធំទាំង ៤ អំពីព្រះមហាក្សត្រិយ៍ ។ ក្នុងក្សត្រីទាំង ៥ អង្គនេះ ព្រះអគ្គមហេសី ធៀបដូចព្រះរាជាម្ចាស់ផែនដី, ព្រះរាជទេវីទាំង ៤ ធៀបដូចមន្ត្រីចតុស្តម្ភ (សេនាបតី) ទាំង ៤ ។ អ្នកដែលនឹងបានជាព្រះអគ្គមហេសីក្តី ព្រះរាជទេវីក្តី ត្រូវមានព្រះជាតិជាក្សត្រិយ៍ បើមានជាតិជារាស្ត្រមកមុន ត្រូវតាំងលើកជាក្សត្រិយ៍សិនហើយ ទើបបានតាំងជាព្រះអគ្គមហេសីឬព្រះរាជទេវី ។ ក្រៅពី ៥ អង្គនេះ ទ្រង់រមែងមានព្រះរាជជាយាផ្សេងៗ មកទៀតជាតិជារាស្ត្រមានច្រើនរូបគ្មានកំណត់ ហៅរួមថា «ព្រះស្រីង្គារ»

ទំនៀមនេះ រាប់ថាជា រាជប្រវេណីរបស់ព្រះមហាក្សត្រិយ៍ខ្មែរ សឹងមានមកពីបុរាណ ។ តែថា ព្រះមហាក្សត្រិយ៍ទាំងឡាយក្នុងអតីតកាលមិនមែនថា សុទ្ធតែទ្រង់កាន់តាមរាជប្រវេណីនេះ គ្រប់ៗព្រះអង្គទេ គឺព្រះអង្គខ្លះ មានតែព្រះអគ្គមហេសី ១ អង្គគ្មានព្រះរាជទេវីសោះ ក៏មាន; ព្រះអង្គខ្លះមានព្រះរាជទេវីតែ ១ អង្គ ឬតែ ២ អង្គ ក៏មាន មិនជាការទៀងទាត់ណាស់ទេ ។

ជាវតាក្លួនថា ពួកស្រីនៅក្នុងព្រះបរមរាជវាំង ក្នុងគ្រានោះ មានរូបឆោមល្អៗណាស់ សំបុរកាយដូចសាច់ចេកក្រូចដូចទឹកដោះ (គឺសំបុរសខ្ចួន មិនមែនសគុះ) ស្លៀកសំឡុយទុកសក់បួងទាំងអស់ ប្រមាណមើលរបៀបបួងសក់ គង់មានវិចិត្រច្រើនបែប ទំនងដូចរូបភាពនាងរបាំ ឬនាងអប្សរដែលគេឆ្លាក់ទុកនៅប្រាសាទថ្ម ។ ពួកស្រីក្រៅព្រះរាជវាំងក៏ទុកសក់បួងនឹងស្លៀកពាក់ទំនងដូចគ្នានេះ ។ ពួកប្រុសសុទ្ធតែស្លៀកសំពត់បង់ក្បិន ។

**ឋានន្តរសក្តិរបស់មន្ត្រី:** អ្នករាជការនៅប្រទេសកម្ពុជា ក្នុងសម័យនោះ មានច្រើនពួក គឺមានក្រុមប្រឹក្សាការផែនដី មានពួកមេទ័ព មានក្រុមហោរ ជាដើម ។ អ្នករាជការផ្នែកជាន់ខ្ពស់ ចែកចេញជា ៤ ពួក មានគ្រឿងយសជាសំគាល់ផ្សេងគ្នា គឺ:

ពួកទី ១ – មានឋានន្តរសក្តិខ្ពស់បំផុត មានសិទ្ធិប្រើមាសនឹងបាំងក្លស់ដងមាសបួន ។

ពួកទី ២ – មានសិទ្ធិប្រើមាស នឹងបាំងក្លស់ដងមាស ១ ។

ពួកទី ៣ – មានសិទ្ធិប្រើប្រាក់ បាំងក្លស់ដងមាស ១ ។

ពួកទី ៤ – មានសិទ្ធិប្រើប្រាក់ បាំងក្លស់ដងប្រាក់ ១ ។

---

១ ខ្ញុំធ្លាប់បានឮចាស់ទុំក្នុងសម័យនេះ មានពួកបារគូជាដើមថា មហេសីរបស់ព្រះរាជា មាន ៣: ទី ១ ហៅ អារ្យអគ្គមហេសី, ទី ២ ហៅ អគ្គមហេសី, ទី ៣ ហៅ មហេសី, តែខ្ញុំសូមបដិសេធថា សេចក្តីយល់បែបនេះមិនត្រូវទេ ។

អ្នកពងការជាន់ទាបចុះមក នៅមានច្រើនពួក ច្រើនផ្នែក ទាំងមានគ្រឿងសំគាល់ផ្សេងទៀត តែមិនមានអធិប្បាយទុកឲ្យច្បាស់លាស់ ទើបសូមស្វែះទុកតែប៉ុណ្ណេះ ។

ពិធីទ្វាទសមាស.— ជាតែក្តួន ក៏មានពោលជល់ខ្វះដែរតែមិនបានសព្វគ្រប់ទាំងអស់, ចំពោះពិធីចូលឆ្នាំរបស់ខ្មែរក្នុងសម័យនោះថា ត្រូវត្រង់ខែទី ១០ របស់ចិន គិតធៀបតាមខែចិនទៅ ត្រូវត្រង់ខែកត្តិករបស់ខ្មែរ ។ តាមដែលបានដឹងមកដោយពិស្តារនោះថា តាំងពីបុរាណកាលរហូតមកដល់ក្នុងរជ្ជកាលព្រះបាទស្រីន្ទ្រវរ្ម័នទី ២ ខ្មែរយើងចូលឆ្នាំក្នុងរវាងដាច់ខែកត្តិក ចូលខែមិគសិរ តែពីដើមឯណោះ ខ្មែរយើងរាប់ខាងរនោចជាដើមខែ ខាងខ្នើតជាចុងខែ; ដូច្នេះ ថ្ងៃដាច់ឆ្នាំចាស់ នៅត្រង់ថ្ងៃ ១៥ កើតខែកត្តិក ថ្ងៃ ១ រោចខែមិគសិរ ជាថ្ងៃទី ១ នៃឆ្នាំថ្មី ព្រោះហេតុនេះ បុរាណទើបកំណត់យកខែមិគសិរជាខែលេខ ១, លេខរៀងបែបនោះប្រើជាប់មកដល់សព្វថ្ងៃនេះ ។ ក្រោយអំពីរជ្ជកាលនេះមកមិនយូរប៉ុន្មាន ខ្មែរយើងបានផ្លាស់យកខាងខ្នើតជាដើមខែ ហើយទុកដាក់ខាងរនោចជាចុងខែវិញ ព្រមទាំងផ្លាស់ពេលចូលឆ្នាំទៅតាមសុរិយគតិ គឺកំណត់បែកដាច់ឆ្នាំចាស់ ចូលឆ្នាំថ្មីនៅត្រង់ថ្ងៃទី ១៥ មេសា បែបនេះបានប្រើដរាបមកដល់ក្នុងបច្ចុប្បន្ន[១] ។ (មានត)

១ ចូរមើលសេចក្តីក្នុងព្រះរាជពិធីចូលឆ្នាំ ក្នុងសៀវភៅព្រះរាជពិធីទ្វាទសមាសរបស់ពុទ្ធ—សាសនបណ្ឌិត្យ ។

# រឿងអារ៉ាត្ស ថ្ងៃដរឿងម្ភៃប្រាំ

## លោកសាង · សាវ៉ាត លេខានុការ ក្រសួងហិរញ្ញវត្ថុ

### ប្រែពីភាសាបារាំងមកជាខ្មែរ

(តមក)

គ្រានោះ ក្សត្រទាំងពីរអង្គបានបីបមថ្នមថើបគ្នាទៅវិញទៅមក, មានពួកស្រីស្នំលំអដោយសំលៀកបំពាក់ភ្លឺផ្លេកបំរុះពណ៌គ្រប់បែប ឈរដង្ហែគ្នាជាជួរទុំបដៃដោយគោរព ៗ នៅខាងម្ខាង មានគ្រែមួយពោរពេញដោយបុប្ផានិងមានផើងទឹកកូឡាប ព្រមទាំងប្រអប់ក្លិនក្រអូបរៀបជាជួរផង ៗ រួចគេឃើញស៊ូកកូឡាបធំ ដែលលំអដោយក្បាច់ពណ៌មាសនិងឈើឯមចម្រុះគ្នា ៗ នោម្ខាងទៀត មានប្រអប់តូចៗ ប្រកបដោយពណ៌ឆើតឆាយ, មានម្ហូបចំណីឆ្ងាញ់ពីសានៅខាងណោះ គឺមានស្ករជុំគ្រប់បែប ៗ មាត់ទ្វារនិងជញ្ជាំង លំអពីលើដល់ក្រោមដោយផ្ទាំងគំនូរនិងតួមនុស្ស ដែលអាចដឹកនាំជនអ្នកមើលឲ្យរីករាយសប្បាយពន់ពេក ៗ

វត្ថុទាំងអស់ដែលជួបជុំគ្នា មានរបៀបរៀបចំល្អបំឡែក ជាហេតុនាំឲ្យមានតម្រេកពុំអាចនិងពណ៌នាបានឡើយ ៗ គឺក្នុងទីនោះហើយដែលព្រះនាងនាំព្រះអង្គចូលទៅ ៗ

លុះព្រះអង្គម្ចាស់ស្ដេចគង់ហើយ ព្រះនាងក៏លាងព្រះបាទាព្រះអង្គម្ចាស់ហើយយកទឹកអប់មកប្រោះព្រំកាយ យកផ្កាកម្រងមកបំពាក់ថ្វាយ

រួចយកទឹកកូឡាបមកស្រឡាបព្រះកាយ ហើយយកផ្លិតមកបក់ថ្វាយទៀត ។

កាលទ្រង់ទតយល់ព្រះនាងធ្វើដូច្នោះ ទើបទ្រង់មានព្រះបន្ទូលថា "ឱប្អូនក្លារអើយ! បងឃើញនាងពេលណា ចិត្តបងត្រជាក់តតនុបមាណា ! ប៉ុន្តែដូចម្តេចក៏ប្អូនធ្វើខ្លួនឲ្យលំបាកដល់ម៉្លេះ? ព្រះហស្តយ៉ាងទន់ភ្លន់របស់នាង មិនមែនសម្រាប់កាន់ផ្លិតនេះទេ! ឲ្យផ្លិតមកបង! ហើយប្អូននាងនៅស្ងៀមចុះ" ។

ព្រះនាងបទ្មវតីឆ្លើយថា: "បពិត្រព្រះសម្មតិទេព! សូមទ្រង់ព្រះមេត្តាប្រោស! ព្រះអង្គទ្រង់យាងមករកខ្ញុំព្រះអង្គដោយលំបាកបំផុតដូច្នេះ ត្រូវតែទូលព្រះបង្គំបម្រើព្រះអង្គ ទោះទើបសមគួរ" ។ ប៉ុន្តែមានស្រីស្នំម្នាក់ បានយកផ្លិតអំពីដៃជនទាំងពីរ ហើយនិយាយថា "នេះជាករណីយកិច្ចរបស់ទូលព្រះបង្គំទេ ទូលព្រះបង្គំនឹងបក់ថ្វាយ សូមទ្រង់ទាំងពីរអង្គក្រេបលំអងនៃបេតីចុះ!" ។

ក្សត្រទាំងពីរព្រះអង្គក៏ទ្រង់សោយព្រះស្ងោយ ដោយបានពិភាក្សាគ្នាទៅវិញទៅមកយ៉ាងស្នេហាបំផុត ។ ប៉ុន្តែដល់ពេលព្រឹកព្រហាមឡើង ព្រះនាងខត្តិយានីក៏លាក់ព្រះអង្គ, លុះដល់វេលាពេត្រឡប់មកវិញ ក្សត្រទាំងពីរពង្សក៏លិចលង់ក្នុងសេចក្តីសប្បាយគ្រប់ប្រាណ ។ ចំនួនច្រើនថ្ងៃកន្លងទៅ ក៏នៅតែដូច្នោះ ។ កាលព្រះមហាក្សត្រមានព្រះ

បន្ទូលអំពីការត្រឡប់ទៅប្រទេសទ្រង់វិញ  ព្រះនាងពុំព្រមព្រះទ័យផង សោះ ។ ក្សត្រទាំងពីរមានវិស្សាសៈស្នេហារ៉ាង១ខែដោយទំនងនេះ ទាល់តែព្រះមហាក្សត្រទុញគុះធុញថប់ព្រួយព្រះទ័យជាពន់ពេក ។

ថ្ងៃមួយនោះ ទ្រង់គង់ម្នាក់ឯង នៅពេលល្ងាច, ទ្រង់គិតដល់ មាតុភូមិព្រះអង្គ នឹងរាជសម្បត្តិ, ព្រះរាជដំណាក់ព្រមទាំងវត្តទាំងប៉ុន្មាន ដែលទ្រង់បានចាកចោល នឹង នឹកដល់សំឡាញ់ដែលបានជួយបំពេញ កិច្ច យ៉ាងម៉ុងម៉ាត់ ទាល់តែទ្រង់បានស្គាល់ស្នេហាធំបំផុតនេះ ហើយពុំ ដែលបានទទួលដំណឹងអ្វីសោះ ។

ព្រះនាងឃើញព្រះអង្គព្រួយដូច្នោះ ទ្រង់មានព្រះបន្ទូលសួរថា: "ឱព្រះបងដ៏ថ្កើងបុណ្យ! តើទ្រង់មានទុក្ខអ្វីបានជាគង់នៅស្ងាត់ស្ងៀម ដូច្នេះ? សូមទ្រង់មានព្រះបន្ទូលប្រាប់អូនផង!!" ។

ព្រះមហាក្សត្រទ្រង់តបវិញថា: "បងមានសំឡាញ់មួយ, បង ស្រឡាញ់ពេញចិត្តណាស់, គេជាកូនរដ្ឋមន្ត្រី; បំនួន ១ ខែមកហើយ បងមិនបានដំណឹងអ្វីអំពីគេសោះ ។ ឯសំឡាញ់នោះមានប្រាជ្ញាណាស់ ទាំងចំណេះវិជ្ជាទៀតសោតក៏វិសេសដែរ គឺដោយសេចក្ដីវៃឆ្លាតរបស់គេ ហើយ បានជាបងបានមកជួបនឹងអូនឯង ព្រោះគេបានពន្យល់បងអំពី ការអាថ៌កំបាំង របស់អូនដោយសព្វគ្រប់" ។

ព្រះនាងក្រាបបង្គំទូលតបទៅវិញថា: "បពិត្រព្រះបងដ៏ថ្កើងឫទ្ធិ! បើព្រះទ័យស្ដេចស្ថិតនៅឯណោះហើយ តើស្ដេចគង់នៅឯណេះ ម្ដេច

ឡើយនឹងបានសប្បាយ, ត្រូវតែប្អូនឱ្យគេយកម្ហូបចំណីគ្រប់មុខ ដែលប្អូនបម្រុងទុកថ្វាយតម្រូវព្រះទ័យព្រះអង្គ; ឯទ្រង់ក៏យាងទៅដែរ រួចត្រូវព្រះអង្គនាំគេជប់លៀងឱ្យបានសប្បាយចិត្តគ្រប់គ្នា ដើម្បីបង្ហាញឱ្យឃើញថា: ក្នុងពេលដែលព្រះអង្គយាងមករកប្អូនម្តងៗ តែងមានព្រះទ័យស្កប់ស្កល់ជាដរាប" ។

លុះទ្រង់ព្រះសណ្តាប់ពាក្យនោះហើយ ព្រះមហាក្សត្រទ្រង់ក្រោកឡើង រួចទ្រង់យាងចេញទៅ ។ ចំណែកព្រះនាងបទុមវតី កាលរៀបចំម្ហូបចំណីសព្វគ្រប់ហើយ បានលួចបន្តក់ថ្នាំពុលជាមួយផង រួចទើបបញ្ជូនទៅ ។

ព្រះអង្គម្ចាស់ពជី-មុកាត បានទៅដល់ក្នុងលោករដ្ឋមន្ត្រី ទ្រង់យាងទៅគង់ជិតបុរសនោះឯង ។ ក្នុងពេលនោះ ម្ហូបចំណីក៏មកដល់ ។ ក្នុងលោករដ្ឋមន្ត្រីសួរថា: "សូមទ្រង់ព្រះមេត្តាប្រោស! តើម្ហូបចំណីនោះមកពីទីណា?" ។

ព្រះមហាក្សត្រទ្រង់ឆ្លើយថា: "ថ្ងៃមួយនោះ ខ្ញុំអង្គុយម្នាក់ឯងដោយក្រៀមក្រំ ព្រោះនឹកដល់សំឡាញ់ឯង ស្រាប់តែព្រះនាងបទុមវតីមកឃើញ ហើយសួរខ្ញុំអំពីដើមហេតុនៃទុក្ខនេះ ។ ខ្ញុំក៏និយាយអំពីតម្រេះរបស់សំឡាញ់ឯង នឹងដំណើរដែលមិត្រឯងរកឃើញការអាថ៌កំបាំងរបស់នាង លុះនាងស្តាប់ខ្ញុំរួច នាងបើកច្បាប់ឱ្យខ្ញុំមកលេងនឹង

មិត្រឯង ហើយបានទាំងផ្ញើរបស់នេះមកមិត្រផង ៗ បរិភោគទៅសំឡាញ់! ចិត្តរបស់ខ្ញុំនឹងរីករាយសប្បាយព្រោះអ្នកពុំខាន!" ៗ

ប៉ុន្តែនៅពេលនោះ កូនលោករដ្ឋមន្ត្រីបានទូលព្រះអង្គវិញថា: "ព្រះអង្គបានយកថ្នាំអាសិរពិសមកឲ្យទូលព្រះបង្គំ, គឺជាសំណាងល្អណាស់ ហើយដែលទ្រង់មិនបានសោយរបស់នេះ សូម្បីតែបន្តិចបន្តួច, សូមព្រះមហាក្សត្រដ៏ថ្កើងបុណ្យទ្រង់ព្រះសណ្ដាប់នូវពាក្យ ដែលចេញអំពីមាត់ទូលព្រះបង្គំនេះចុះ: · ជាតិជាស្រីមិនដែលស្រឡាញ់របស់ប្ដីខ្លួនទេ ចំណែកខាងព្រះអង្គ ពិតជាទ្រង់ឈ្លេងណាស់ ព្រោះទ្រង់ប្រាប់ឈ្មោះទូលព្រះបង្គំដល់ព្រះនាង· ៗ

ព្រះមហាក្សត្រមានព្រះរាជឱង្ការថា: "ក្រៅអំពីមិត្រ គ្មានអ្នកណាមួយហ៊ាននិយាយពាក្យអស់នេះប្រាប់ខ្ញុំទេ, បើមនុស្សមិនខ្លាចមនុស្សក៏គង់មនុស្សខ្លាចទេព្ដាដែរ" ៗ លុះមានព្រះបន្ទូលរួច ព្រះអង្គម្ចាស់បានយកម្ហូបមួយមុខ បោះទៅឲ្យឆ្កែស៊ី ឆ្កែនោះស៊ីរួចក៏ប្រកាច់ស្លាប់មួយរំពេចភ្លាម ៗ កាលទ្រង់ឃើញដូច្នោះ ព្រះអង្គម្ចាស់ទ្រង់ខ្មាសជាពន់ពេក ហើយមានព្រះបន្ទូលថា: "មិនគួរគាប់នឹងកប់ប្រសប់ជាមួយស្រីអាក្រក់បែបនេះសោះ ៗ តាំងពីថ្ងៃមុនមកទល់ថ្ងៃនេះ ខ្ញុំបានចិញ្ចឹមចិត្តស្រឡាញ់នាងយ៉ាងស្មោះស្ម័គ្រ ប៉ុន្តែក្នុងពេលនេះលែងអស់ហើយ" ៗ

— ឥឡូវនេះសូមព្រះអង្គធ្វើដូច្នេះវិញ, សូមស្ដេចនាំនាងមកក្នុងដំណាក់ព្រះអង្គឲ្យបាន ៗ

ព្រះមហាក្សត្រមានព្រះពជនុគ្គារថា "មិនអីទេសំឡាញ់! បំណងរបស់អ្នកនឹងសម្រេចពុំខាន" ។

កូនលោកវដ្ដមន្ត្រីនិយាយទៀតថា "សូមព្រះអង្គទ្រង់ធ្វើឲ្យបានសម្រេចក្នុងថ្ងៃនេះ; សូមទ្រង់យាងត្រឡប់ទៅរកព្រះនាង ហើយសូមទ្រង់ធ្វើតាមពាក្យទូលព្រះបង្គំកុំខាន; លុះទៅដល់ជិតនាងហើយ សូមព្រះអង្គធ្វើហាក់ដូចជាស្រឡាញ់នាងលើសប្រមាណ, កាលណាព្រះនាងផ្ដួលក់ហើយ សូមទ្រង់ដោះយកគ្រឿងមាសពេជ្រអំពីព្រះនាងឲ្យអស់រួចត្រូវចាក់ភ្លៅព្រះនាងខាងឆ្វេង ១ ប្រូកដែលមានថ្លៃ ហើយត្រូវយាងត្រឡប់មកវិញយ៉ាងប្រញាប់ ។

កាលទ្រង់ព្រះសណ្ដាប់សព្វគ្រប់ហើយ លុះដល់វេលាយប់ព្រះអង្គម្ចាស់ ក៏យាងទៅដំណាក់ព្រះនាងបទុវតី ហើយស្ដេចទ្រង់មានព្រះពជនុគ្គារយ៉ាងស្និទ្ធស្នាលទៅរកព្រះនាង, ស្រេចហើយក៏ផ្ដួលក់ទាំងពីរព្រះអង្គទៅ ។

បន្ទាប់មកព្រះមហាក្សត្រ ទ្រង់រង់ចាំឱកាស ឲ្យព្រះនាងលក់ស៊ប់លុះព្រះនាងផ្ដួលក់ស៊ប់ហើយ ព្រះអង្គក៏ដោះយកគ្រឿងអលង្ការទាំងអស់រួចចាក់ភ្លៅឆ្វេងព្រះនាង ១ ប្រូក ទើបត្រឡប់មកដំណាក់ព្រះអង្គវិញភ្លាមហើយបាននិទានរឿងរ៉ាវនោះ ប្រាប់កូនលោកវដ្ដមន្ត្រី ព្រមទាំងបង្ហាញគ្រឿងអលង្ការទាំងអស់ផង ។ ឯកូនលោកវដ្ដមន្ត្រីបានយកគ្រឿង

អលង្ការនោះមកស្លៀកពាក់ជាអ្នកសុំ ដើរឆ្ពោះទៅកាន់ម៉ឺនខ្មោចជាមួយព្រះអង្គម្ចាស់ ហើយបានអង្គុយក្បែរម៉ឺននោះ ។ លុះទៅជាអ្នកសុំ ហើយទាំងបានធ្វើព្រះអង្គម្ចាស់ឲ្យទៅជាសាវករបស់ខ្លួនស្រេច ទើបនិយាយទូលព្រះអង្គម្ចាស់ថា "សូមស្តេចយកគ្រឿងប្រដាប់នេះ ទៅលក់ឯផ្សារ បើប្រសិនជាមានអ្នកណាមកចាប់ព្រះអង្គ សូមទ្រង់នាំគេមករកទូលព្រះបង្គំចុះ" ។

កាលណោះ ព្រះអង្គម្ចាស់បានយកគ្រឿងអលង្ការទាំងប៉ុន្មានទៅឯទីក្រុង ហើយបានបង្ហាញដល់ជាងមាសម្នាក់ ដែលនៅជិតមាត់ទ្វារស្តេច ជាងមាសឃើញគ្រឿងប្រដាប់នោះក៏ស្គាល់ជាក់ហើយនិយាយថា: "គ្រឿងប្រដាប់នេះជារបស់ព្រះនាងកល្យាណីក្សត្រីទេ, ចូរអ្នកប្រាប់ការពិតមកខ្ញុំ តើអ្នកបានពីទីណាមក?" ។

ក្នុងពេលដែលជាងមាសនិយាយដូច្នោះ មានមនុស្សចំនួនពីដប់ទៅម្ភៃនាក់បានមកជួបជុំគុះគរ ឯលោកនាយក្រុមព្រះនគរបាលលុះដឹងដំណឹងនេះច្បាស់ប្រាកដ ក៏ចាប់ព្រះអង្គម្ចាស់ព្រមទាំងគ្រឿងអលង្ការនិងជាងមាសទៅផង ហើយបានសួរព្រះអង្គម្ចាស់ថា "តើអ្នកបានគ្រឿងប្រដាប់នេះពីណាមក?" ។ ព្រះអង្គម្ចាស់ឆ្លើយថា: អ្នកសុំឲ្យខ្ញុំយកមកលក់ ប៉ុន្តែខ្ញុំមិនបានដឹងជាគ្រឿងប្រដាប់នេះមកពីណាទេ" ។ គ្រានោះ លោកនាយក្រុមព្រះនគរបាល ក៏ចាប់អ្នកសុំមកទៀត

រូបបានបញ្ជូនជនទាំងពីរទៅថ្វាយព្រះមហាក្សត្រម្ចាស់ផែនដី ព្រមទាំងគ្រឿងប្រដាប់នោះផង ហើយបានក្រាបបង្គំទូលដោយសព្វគ្រប់ ។

លុះស្ដេចទ្រង់ព្រះសណ្ដាប់ហើយ ទ្រង់សួរទៅអ្នកសច្ចំថាៈ "តើលោកតាបានគ្រឿងប្រដាប់នេះពីណាមក?" ។

— សូមទ្រង់ព្រះមេត្ដាប្រោស! ទូលព្រះបង្គំបានទៅក្នុងម៉ុងខោចពីថ្ងៃ ១៤ កើតនេះ ដើម្បីទៅសូត្រមន្ដអាគមគាថា ដែលត្រូវធ្វើឲ្យទូលព្រះបង្គំឃើញរូបព្រាយមួយ; លុះរូបព្រាយនោះមកដល់ហើយ ទូលព្រះបង្គំក៏បានដោះយកគ្រឿងប្រដាប់នឹងសម្លៀកបំពាក់វា ហើយបានទាំងចាក់ភ្លៅឆ្វេងវាមួយចប្រកដែលមានផ្លែ ៣ ផង ។ ដោយហេតុនេះហើយបានជាទូលព្រះបង្គំបានគ្រឿងប្រដាប់នេះមក ។

ព្រះករុណាទ្រង់ព្រះសណ្ដាប់ពាក្យអ្នកសច្ចំហើយ ស្ដេចក៏ទ្រង់ថយព្រះអង្គចូលទៅក្នុងព្រះដំណាក់វិញ ឯអ្នកសច្ចំក៏បត់ជើងនៅលើគ្រែលរបស់លោកដដែល ។ ក្សណនោះព្រះមហាក្សត្រទ្រង់មានព្រះរាជឱង្ការទៅព្រះអគ្គមហេសីថាៈ "ចូរប្អូនទៅមើល! តើភ្លៅឆ្វេងរបស់នាងបទុវតី មានស្នាមឬទេ ហើយចូលសង្កេតមើល តើស្នាមយ៉ាងណា? ។ ព្រះរាជអគ្គមហេសីក៏យាងទៅ ហើយទ្រង់ទតឃើញស្នាមចប្រកធ្មេញ ៣ ។ លុះត្រឡប់មកវិញទើបមានព្រះសវនីយទូលព្រះរាជាថាៈ "សូមទ្រង់ព្រះសណ្ដាប់ ភ្លៅរបស់នាងមានស្នាម ៣ មើលទៅហាក់ដូចជាស្នាមចប្រកផ្លែ ៣ ហើយយ៉ាង? ។

ព្រះរាជាទ្រង់ព្រះសណ្ដាប់ពាក្យនោះហើយ ស្ដេចក៏យាងចេញមក រួចទ្រង់ត្រាស់បង្គាប់ទៅលោកនាយកក្រុមព្រះនគរបាល ឲ្យហៅអ្នកសបុំមកម្ដងទៀត ។ ក្នុងពេលដែលលោកនាយកក្រុមព្រះនគរបាលកំពុងធ្វើតាមព្រះរាជបញ្ជានោះ ស្ដេចទ្រង់ព្រះចិន្ដាថា "មិនគួរឲ្យអ្នកណាមួយដឹងរឿងក្នុងព្រះបរមរាជវាំងសោះ ជាហេតុនាំឲ្យអាម៉ាស់មុខណាស់" ។

ក្នុងពេលនោះ រាជអាមាត្យបាននាំអ្នកសបុំមកដល់ហើយឲ្យអង្គុយកន្លែងមួយដោយឡែក ទើបព្រះមហាក្សត្រទ្រង់សួរថា: "ឱ! អ្នកសបុំជាទីគោរពអើយ! បើវិនិច្ឆ័យតាមគម្ពីរនោះ តើទោសយ៉ាងណាដែលត្រូវដាក់ដល់រូបមនុស្សស្រី?" ។

អ្នកសបុំឆ្លើយទូលថា: "បពិត្រព្រះមហាក្សត្រដ៏ប្រសើរបារមី! គម្ពីរបានប្រាប់សេចក្ដីថា ព្រាហ្មណ៍, សេះ, ស្ដ្រី, កូនក្មេង, ឬអ្នកណាក៏ដោយ ដែលនៅក្រោមអធិបតីភាពរបស់ព្រះអង្គ ហើយបានប្រព្រឹត្តអំពើអាក្រក់នោះ ត្រូវតែនិរទេសបោលដោយដាច់ខាត" ។

លុះព្រះមហាក្សត្រទ្រង់ឮដូច្នោះ ទើបទ្រង់មានព្រះរាជបញ្ជាឲ្យនាងបទ្មវតីឡើងជិះរទេះមួយ រួចនិរទេសបោលក្នុងព្រៃទៅ ។ ឯព្រះអង្គម្ចាស់ខឹងកូនលោករដ្ឋមន្ត្រី ក៏ឡើងជិះសេះ ១ ម្នាក់ទៅតាមព្រះនាងក្នុងព្រៃ ហើយនាំព្រះនាងទៅស្រុករបស់ខ្លួនទៅ ។ អស់ចំនួនប្រាំថ្ងៃ ជនទាំងពីរក៏បានទៅជួបមុខបិតារៀងៗខ្លួន ។ ឯអស់នាម៉ឺនសព្វ

មុខមន្ត្រីទាំងធំ-តូច ក៏បានស្គាល់សេចក្ដីក្រមក្សាន្តយ៉ាងធំ ព្រមទាំងមានការជប់លៀងយ៉ាងអ៊ឹកអធិកធង ។

លុះនិយាយរឿងនេះហើយ ទើបអារក្សទូលទៅកាន់ស្ដេចពិករ័នថា: "មើល! បណ្ដាជនទាំងអស់ តើអ្នកណាខ្វះគេអាចបន្ទោសបាន?, បើស្ដេចឆ្លើយមិនសមទេ ព្រះអង្គនឹងធ្លាក់ទៅក្នុងអវីចិនរកពុំបាន" ។

ស្ដេចពិករ័ន្ទទ្រង់ឆ្លើយថា: "គឺព្រះមហាក្សត្រហើយដែលខុសនោះ" ។ អារក្សសួរទៀតថា: "ហេតុដូចម្ដេចបានជាស្ដេចខុស?" ។

ស្ដេចពិករ័នទ្រង់តបថា: "កូនលោកជេដ្ឋមន្ត្រីបានជួយបំពេញកិច្ចធុរៈទៅហ្វាយនាយរបស់ខ្លួន, មេនាយកក្រុមព្រះនគរបាល បានស្ដាប់បង្គាប់ស្ដេចរបស់ខ្លួន, ឯព្រះនាងកល្យាណីក្សត្រី បានឃើញបំណងរបស់នាងដែលសម្រេច ។ បើដូច្នោះ គឺស្ដេចហើយដែលខុសនោះ ព្រោះស្ដេចនិរទេសនាងដោយឥតគិត" ។ និមិត្តតែកិរិយាត្រូវព្រះរាជ-ឧង្ការនោះ អារក្សក៏ត្រឡប់ទៅដើមឈើរបស់ខ្លួនវិញ ។ ព្រះមហាក្សត្រលុះទតជុំវិញព្រះអង្គពុំឃើញអារក្សនោះ ក៏ទ្រង់ត្រឡប់ទៅកន្លែងចាស់ដែលព្រះអង្គយាងមក ទ្រង់ឡើងទៅលើដើមឈើនោះ បានចងអារក្សលីលើស្មារួចទើបយាងទៅទៀត ។

ចំណែកខាងអារក្សបានក្រាបបង្គំទូលព្រះអង្គថា: "ឳ! ព្រះមហា-ក្សត្រ! ឯរឿងទី ២ របស់ទូលព្រះបង្គំនោះមាន ដូចតទៅនេះ:–

(មានត)

# ដំណើរមកកាន់ប្រទេសកម្ពុជា

## នៃមហាបណ្ឌិតគុណបាលបិយសេន ម៉ាឡ៉ាល៉ៈសេកេរៈ

### ជាអធិបតីពុទ្ធិកសមាគមពិភពលោកនៅលង្កាទ្វីប

## របស់ពុទ្ធសាសនបណ្ឌិត្យ

(តកម)

---

សម្តេចប្រទេសជប៉ុន ដែលមានអារាមជាចំណុះ ចំនួន ១៤.០០០ វត្ត ក៏បាននិមន្តទៅដែរ ។ កោះហាវ៉ៃដែលមានប្រជាជន ៧៨.០០០ នាក់ មានអ្នកតំណាង ២ នាក់ទៅប្រជុំ ។ យួនមានអ្នកតំណាង ៣ នាក់, ប៉ាគីស្ថានមាន ៤ នាក់ គឺ ២ នាក់ជាលោកសង្ឃ, ២ នាក់ទៀតជាឧបាសក ។

ខ្ញុំមិនបាច់ជំរាបរឿងនេះឲ្យវែងពេកទេ ព្រោះលោក-អ្នកប្រហែលជាបានជ្រាបអំពីសម្តេចសង្ឃនាយកសព្វគ្រប់អស់ហើយ ។ ដូច្នេះខ្ញុំសូមជំរាបតែអំពីទីកន្លែងដែលប្រជុំនោះវិញ ។

ទីកន្លែងនុះ មិនធ្លាប់បើកប្រជុំពីកាលណាមកទេ ទើបតែទីងមានក្នុងពេលនេះដែលជាលើកដំបូងបង្អស់ ។ មុននឹងប្រជុំ គេបានទៅនិមន្តព្រះបដិមាកែវមកដំកល់ជាប្រធាន ។ ក្នុងពេលនោះគួរឲ្យអស្ចារ្យណាស់ មហាមេឃដែលហួតហែង ៤ ខែមកហើយ ក៏បង្អុរភ្លៀងយ៉ាងបង្គួរចំនួនកន្លះម៉ោង ហើយរុក្ខជាតិក៏បានស្រស់ញញឹមឡើង ដូចជាមានសេចក្តី

អបអរសាទរនឹងឧត្តមគតិនៃទីប្រជុំ ដែលមានការចង់ឲ្យរួបរួមគ្នា ជាគោលបំណងធំនោះផង ។ អាកាសក៏ត្រជាក់ស្រួល, ទេសភាពនៃទីក្រុងក៏បានប្រលោមចិត្តភ្ញៀវទាំងនោះ ឲ្យចេះតែមានអធ្យាស្រ័យស្រុះស្រួលគ្នាជានិច្ច ។

ក្នុងថ្ងៃទីពីរ មានប្រជុំធំមួយទៀត ដែលមានលោកនាយករដ្ឋមន្ត្រីប្រទេសលង្កាបានអញ្ជើញទៅជាអធិបតី ។ ក្នុងពេលនោះ មានប្រជាជនទៅជួបជុំប្រហែល ២០.០០០ នាក់ រួមទាំងសមាជិកដែលមកពីប្រទេស-ផ្សេងៗ យ៉ាងច្រើននោះផង ។ ដូច្នេះ ការជ្រើសរើសរកទីកន្លែងឲ្យបានសមរម្យ ក៏ជាបញ្ហាមួយយ៉ាងលំបាកបំផុត ។ មានអ្នកខ្លះបន្ទោសខ្ញុំថា ខ្ញុំមិនគួរនឹងយកវាលប្រណាំងសេះ ទៅធ្វើជាទីសន្និបាតព្រះពុទ្ធសាសនា ដែលជាទីគោរពយ៉ាងខ្ពង់ខ្ពស់របស់ប្រជាជនដូច្នោះទេ ។ ត្រង់រឿងនេះ ខ្ញុំសូមឆ្លើយថា វាលប្រណាំងសេះនោះ មិនមែនជាទីកន្លែងបោកទាបដូចស្មាននោះឡើយ ព្រោះកន្លែងនេះក៏ដូចជាព្រះវិហារមួយដែរ ដ្បិតនៅពេលប្រជុំនោះ ខ្ញុំបានឲ្យយកព្រះពុទ្ធរូបទៅតាំង ដើម្បីឲ្យទីកន្លែងនោះឡើងឋានៈទៅជាព្រះវិហារមួយយ៉ាងសុទ្ធសាធ ។

ការពិភាក្សាបានធ្វើយ៉ាងយូរ តាំងពីថ្ងៃទី ២៥ ឧសភា នៅថ្ងៃទី ៦ មិថុនា ទើបសម្រេច, រួចហើយក៏បាននាំគ្នាទៅប្រជុំនៅអនុរាធបុរៈដែលជាទីក្រុងចាស់នោះទៀត ដោយមានការរៀបចំទទួលយ៉ាងអឹកធឹក ។

បរិយាកាសនៃការប្រជុំ ដែលបានធ្វើដោយការយោគយល់ចិត្តគ្នាជាបំផុត បាននាំឲ្យមេត្រីភាពដែលមានការមួហ្មងជាយូរមកហើយនោះ បានភ្លឺត្រចះឡើងវិញ ព្រោះគេទាំងឡាយមានការពាក់ទាក់នឹងគ្នាដូចជាបងប្អូនបង្កើត ។ ការប្រស្រ័យគ្នា ដូចជាគ្មានប្រកួតប្រកាន់និកាយអ្វីទេក្នុងទីប្រជុំគ្នានេះ ។ ដូច្នេះ ឃើញថាកិច្ចនេះជាជំហានដំបូងបង្អស់របស់ពុទ្ធសាសនិកជនទាំងឡាយ ដែលឈមមុខទៅកាន់ការរួបរួមគ្នាដែលបានបាត់បង់ជាច្រើនសតវត្សមកហើយ ។

អស់លោក-អ្នកដ៏ចំរើនទាំងឡាយ! ក្នុងពិភពលោកយើងនេះ អ្នកកាន់ពុទ្ធសាសនាមានចំនួន ២៨,៦ % ។ ចំនួននេះ ឃើញថាច្រើនជាងអ្នកកាន់សាសនាដទៃ គឺអ្នកកាន់សាសនាគ្រិស្តមានចំនួនតែ ១៦,៧% អ្នកកាន់សាសនាព្រាហ្មណ៍ ១២,៣ % អ្នកកាន់សាសនាឥស្លាម ១៣,៦ %-។ល។ ប៉ុន្តែបើធៀបនឹងចំនួនប្រជាជនក្នុងពិភពលោកទាំងមូល ដែលមានដល់ទៅ ២.២៦៥ លាននាក់នោះ អ្នកកាន់ពុទ្ធសាសនាសព្វថ្ងៃនេះមានតែ ៣៥០ លាននាក់ នៃប្រទេសទាំង ៦២ នោះ ។ ដូច្នេះឃើញថាមិនទាន់ជួនល្មមនៅឡើយ ។ ប្រសិនបើប្រទេសទាំងឡាយ ក្នុងពិភពលោកបានកាន់ពុទ្ធសាសនាទាំងអស់គ្នា ដែលជាសាសនាប្រដៅឲ្យទំលាក់អាវុធចេញ នោះមុខជាសង្គ្រាមគ្មានក្នុងលោកទេ ព្រោះមិនអាចនឹងទំលាយកំពែងនៃសាមគ្គីធម៌ របស់ពុទ្ធបរិសទ្យបានឡើយ ។

ក្នុងពេលដែលទុក្ខមគតិរបស់យើង កំពុងតែត្រូវការទីងធ្វើដំណើរ ផ្សាយសាសនា តាមគន្លងនៃបុព្វបុរសរបស់យើងនោះ យើងគួរឲ្យមាន សេចក្ដីស្វាយជាទីបំផុត ចំពោះការណ៍ដែលប្រទេសកាន់ពុទ្ធសាសនា ទាំងឡាយបានបែកសាមគ្គីគ្នា ព្រោះតែការប្រកាន់និកាយ ដែលមានវត្ត ប្រតិបត្តិខុសគ្នាបន្តិចបន្តួច ។

យើងជាកូនព្រះពុទ្ធតែមួយព្រះអង្គ សេចក្ដីប្រតិបត្តិរបស់យើង ក៏ធ្វើទៅតាមព្រះធម៌នៃព្រះពុទ្ធតែមួយព្រះអង្គដែរ; ដូច្នេះ យើងត្រូវជា បងប្អូននឹងគ្នា ហើយទុកជាពេលណាក៏ដោយ ក៏យើងមិនត្រូវប្រកួត ប្រកាន់គ្នាឡើយ ។

ការខ្វែងគំនិតគ្នាក្នុងផ្លូវប្រតិបត្តិ ជាទោសមួយយ៉ាងធំក្នុងការនាំឲ្យ បែកសាមគ្គីនេះ, គ្មានបណ្ដាលមកពីអ្វីទេ បណ្ដាលមកតែអំពីការ រៀនសូត្រ ដែលមិនបានធ្វើឲ្យស្របយោបល់ជាមួយគ្នា ។ សព្វថ្ងៃនេះ អ្នកកាន់ពុទ្ធសាសនាបែកទៅជា ២ និកាយ គឺពួកមហាយាននឹងពួក ហីនយាន ។ ពួកហីនយានថាពួកមហាយានមិនសូវល្អទេ ព្រោះមាន ព្រះច្រើនព្រះអង្គណាស់, ប៉ុន្តែពួកហីនយានឯងក៏មានព្រះច្រើនណាស់ ដែរ គឺមានដល់ទៅ ២៨ ព្រះអង្គ ហើយនឹងច្រើនជាងនេះទៅទៀត ដូចមានប្រាកដក្នុងនមក្ការអដ្ឋការគាថា (ធម៌សម្ពុទ្ធេ) ជាដើមយ៉ាង ។ ខាងមហាយានថាពួកហីនយានឆាន់សាច់សត្វ មិនល្អទេ ។ ពួកហីនយាន ក៏លើកទោសថា ពួកមហាយានឆាន់អាហារយប់មិនល្អដែរ ។

ឥឡូវបើយើងបេះតែជជែកគ្នារកខុសរកត្រូវ ហើយផ្ដិតយកតែត្រូវរៀងខ្លួននោះ ក៏បេះតែមានខុសតទៅទៀត ៗ ដូច្នេះយើងគប្បីតែលើកលែងទោសគ្នា លែងប្រកួតប្រកាន់គ្នានោះ ទើបនឹងអាចញ៉ាំងសាមគ្គីធម៌ឲ្យកើតឡើងបាន ។

អ្នកផងគង់បានជ្រាបហើយថា សាមគ្គីធម៌នេះ មិនអាចនឹងកើតមានបាន ក្រៅពីការប្រជុំសម្រុះសម្រួលគ្នាដោយយល់ចិត្តយល់ថ្លើមគ្នានោះទេ ។ ដូច្នេះ ហើយបានជាសមាគមពិភពលោក អញ្ជើញប្រទេសទាំងឡាយដែលកាន់ពុទ្ធសាសនា ទៅរួមប្រជុំ ដើម្បីនឹងសំរុះសំរួលអំពីប្រស្នាដែលខ្វែងគំនិតគ្នាផ្សេងៗ ។ មានប្រស្នាជាច្រើនណាស់ដែលបំរុងនឹងលើកយកមកដោះស្រាយ ប៉ុន្តែបញ្ហាដែលបានដោះស្រាយរួចហើយនោះ គឺការកំណត់ថ្ងៃធ្វើវិសាខបូជា ឲ្យបានត្រូវគ្នាហើយនឹងទូទាំងសាសនា ។

វិសាខបូជានេះ ប្រទេសខាងមហាយាន មានប្រទេសចិន, ជប៉ុន, ទីបេត៍ ជាដើម បានធ្វើមុនយើងមួយអាទិត្យ ហើយគេរិះគន់ថាពួកហីនយានភ័ន្តច្រឡំថ្ងៃបរិនិព្វាននៃព្រះសម្មាសម្ពុទ្ធ ។ ខ្ញុំបានស្នើរឿងនេះ ដោយសុំឲ្យពួកមហាយានកំណត់យកតាមថ្ងៃដែលពួកហីនយានធ្លាប់ធ្វើនោះវិញ ព្រោះឃើញថាពួកហីនយាន មានឡាក់ហានគ្រប់គ្រាន់ជាង ។ សភាកុងគ្រេស៍បានកំណត់យកពេលម៉ោង ៨ នៃថ្ងៃ ១

ពេចវិសាខ ជាពេលសំរាប់សូត្រគាថាបូជា ។ ប្រទេសទាំង ១៦ ក៏បានយល់ព្រមតាមសេចក្ដីសំរេចនេះ ។

ចំណែកខាងទង់សាសនា ដែលមានផ្សេងៗគ្នា ទៅតាមសេចក្ដីពេញចិត្តនៃប្រទេសនោះៗ ក៏បានត្រូវយកមកសំរេចក្នុងសន្និបាតនេះដែរ: មានសមាជិកគ្រប់ប្រទេស បានស្នើទង់រៀងខ្លួន ។ លុះពិភាក្សាទៅ ក៏បានសំរេចយកទង់ដូចមានរូបប្រាកដមកក្នុងពេលនេះ ដើម្បីឲ្យងាយធ្វើផង តម្រូវទៅតាមឆព្វណ្ណរង្សីនៃព្រះសម្មាសម្ពុទ្ធផង ។

គឺថ្ងៃវិសាខបូជានេះហើយ ដែលជាថ្ងៃបើកសកកាជថ្មី នៃទង់សាសនាដែលទើបនឹងបង្កើតនោះ នៅគ្រប់ប្រទេសកាន់ពុទ្ធសាសនា ។ គេបានចាប់ផ្ដើមដោតទង់នេះក្នុងថ្ងៃជាមួយគ្នា ហើយធ្វើវិសាខបូជាត្រូវថ្ងៃគ្នាទៀត ។ នៅប្រទេសសៀមនឹងភូមា, តែកាលណាគេដំឡើងទង់ជាតិគេហើយ គេក៏ដំឡើងទង់សាសនានេះជាមួយផងដែរ ។

មានប្រស្នាចាក់ស្រេះជាច្រើនទៅទៀត ដែលពុំទាន់បានលើកយកមកដោះស្រាយ មានប្រស្នាខាងការប្រកាន់ពួកគណៈជាដើម ។ នៅប្រទេសលង្កា ក៏មានព្រះសង្ឃបែកគ្នាជានិកាយដែរ មានដល់ទៅ ៣ ពួក គឺ ស្យាមនិកាយ, រាមញ្ញនិកាយ នឹងមរម្មនិកាយ ។ ព្រះសង្ឃក្នុងនិកាយទាំងនេះ មិនបានរួបរួមសង្ឃកម្មគ្នាទេ ប៉ុន្តែខាងគ្រហស្ថប្រុសស្រីមានសេចក្ដីរាប់អានគ្នាដូចបងប្អូនបង្កើត ដោយឥតគិតដល់ពួកគណៈណាមួយឡើយ ។

នៅប្រទេសខ្លះ ព្រះសង្ឃដែលខុសនិកាយគ្នា មិនព្រមនាំរួមគ្នាទេ ទុកជាមានការបង្ខំយ៉ាងណាក៏ដោយ ។ ការបែកខ្ញែកគ្នានេះ បើប្រសិនជាអ្នកណាមួយអាចរួបរួម ឲ្យបានសម្រេចដូចបំណងបាននោះ ក៏ជាការប្រសើរណាស់ ។ គួរឲ្យនឹកធ្ងល់ណាស់ដែរ ! ពួកឧបាសកឧបាសិកាដែលមានសំលៀកបំពាក់ប្លែកៗគ្នា, គេចេះទៅមករកគ្នា ចេះប្រស្រ័យគ្នា ដោយមេត្រីភាពយ៉ាងស្មោះសរ ដូចបងប្អូនបង្កើត ! ចុះចំណែកខាងព្រះសង្ឃក្នុងព្រះពុទ្ធសាសនាវិញ ដែលមានសំលៀកបំពាក់ដូចគ្នាផង កាន់សាសនាព្រះពុទ្ធត្រូវគ្នាផង ហេតុម្តេចក៏មិនទៅមករកគ្នា ? ហេតុអ្វីក៏ធ្វើកិរិយាព្រងើយកន្តើយនឹងគ្នា ដែលមិនសមជាជាបងប្អូនរួមសាសនាជាមួយគ្នាសោះ ? ។

កុំថាឡើយដល់ទៅសេចក្តីប្រតិបត្តិ, សូម្បីសំលៀកបំពាក់នៃព្រះសង្ឃសព្វថ្ងៃនេះ ក៏មិនត្រូវគ្នាដែរ, ខ្លះប្រើពណ៌ខ្មៅ, ខ្លះពណ៌លឿង, ខ្លះប្រើស្បង់ចីពរ, ខ្លះប្រើខោអាវ ។ ខ្ញុំមិនដឹងនឹងរកឧបាយធ្វើយ៉ាងដូចម្តេចទេ ដើម្បីឲ្យព្រះសង្ឃទាំងនេះជានឹងគ្នាវិញបាន, ប៉ុន្តែមានមធ្យោបាយមួយដែលខ្ញុំនឹកស្មានទៅ គឺទាល់តែបើកឲ្យមានការរៀនជាមួយគ្នា ហើយនឹងបើកប្រជុំគ្នាជាញឹកញយ ។ ដែលយើងមិនរៀនជាមួយគ្នា មិនប្រជុំញឹកញយនោះ ជាហេតុនាំឲ្យមានការលាក់គំនិតគ្នាហើយនឹងបែកខ្ញែកយោបល់គ្នា ក្នុងការប្រតិបត្តិផ្សេងៗ ។ តាមបំណងរបស់ខ្ញុំ,

ខ្ញុំចង់ទុកប្រទេសលង្កាជាមជ្ឈមណ្ឌលនៃការសិក្សា ព្រោះបើកាលណាព្រះសង្ឃទាំងឡាយនោះរៀនចេះដឹងត្រូវគ្នាហើយ នឹងបើកប្រជុំនិយាយគ្នាពីរឿងនេះ ។

ខ្ញុំបានដឹងច្បាស់ហើយថា ដែលនឹងមាននាទីនិយាយគ្នាពីរឿងនេះបាន ទាល់តែសម្ដេចសង្ឃនាយកនៃប្រទេសទាំងឡាយ, ព្រោះបើកាលណាអ្នកធំៗ រួមគ្នាហើយ អ្នកតូចៗ ក៏មុខជានឹងរួមគ្នាទៅឯង ។ ប៉ុន្តែដើម្បីឲ្យងាយដល់ការរួបរួមជាងនេះទៅទៀត មានតែត្រូវរៀនសូត្រឲ្យចេះដឹងដូចគ្នាសិន ។

នៅប្រទេសយើង, ពួកក្មេងៗ ក៏កាន់សាសនាដែរ, តែបើគេសួរទៅវាៗ ក៏មិនអាចនឹងឆ្លើយតបអ្វីបានឡើយ ។ យ៉ាងនេះនាំឲ្យការដោះស្រាយបញ្ហារបស់យើង ត្រូវងាកទៅរករៀបចំការអប់រំក្មេងនោះផង ព្រោះការអប់រំពីតូចៗ ជាការសំខាន់ណាស់ របែកខាងជំនឿ ។ សន្ដានរបស់ក្មេងងាយនឹងពត់ជាបំផុត ។ បើប្រសិនជាវាទៅរៀននៅសាលាឯទៀត ដែលមានបង្រៀនតែសាសនាដទៃ នោះវាក៏នឹងបាក់ចិត្តជឿតាមតែសាសនាណា ដែលគេបានបង្ហាត់បង្រៀនវាដោយហ្មត់ចត់ គឺធម្មជាតិរបស់វាតែងតែរេទៅតាមគេញាក់ជាដរាប ។

តាមសេចក្ដីសង្កេតរបស់ខ្ញុំ, ក្នុងដំណើរទស្សនាការ ដែលខ្ញុំទើបនឹងបានធ្វើមកនេះ ឃើញថានៅក្នុងសាលារៀនរាជការក្នុងប្រទេសកម្ពុជា

គ្មានបញ្ចូលដំបូន្មានខាងពុទ្ធសាសនា នៅក្នុងកម្មវិធីនៃការបង្ហាត់បង្រៀនទេ ៗ របៀបនេះ នឹងហុចផលមកឲ្យវិញផ្ទុយគ្នានឹងសេចក្តីត្រូវការរបស់ប្រទេសយើង ព្រោះយុវទៅកូនចៅយើងមុខជានឹងរវាតចិត្តលែងជឿពុទ្ធសាសនាពុំខាន ៗ ចំណែកនៅប្រទេសខ្ញុំ គេបានបញ្ចូលវិជ្ជាពុទ្ធ-សាសនាទៅក្នុងថ្នាក់សូត្រនៃការសិក្សាជាតិដែរ មកជាយូរឆ្នាំហើយ ៗ

ម្យ៉ាងទៀត ខ្ញុំសង្កេតឃើញនៅប្រទេសកម្ពុជានេះ គ្រូបង្រៀនស្រីៗ នៅមានចំនួនតិចណាស់ ដែលត្រូវតែជួលគ្រូជាតិដទៃមកបង្ហាត់បង្រៀន ៗ ការជួលជាតិគេនេះ មិនជាការប្រពៃទេ ព្រោះគ្រូដែលយើងជួលនោះ មុខជាមិនបង្រៀនសាសនា តាមសេចក្តីត្រូវការរបស់យើងឡើយ ៗ មិនមែនតែនៅប្រទេសកម្ពុជាទេ សូម្បីប្រទេសរបស់ខ្ញុំក៏មានទំនងដូចគ្នានឹងប្រទេសនេះដែរ ៗ ដូច្នេះ យើងត្រូវតែដោះស្រាយបញ្ហានេះ ដោយពួកដែរៀនសូត្រទាំងអស់គ្នា ពួកដែលបំរើប្រទេសទាំងអស់គ្នាឡើង ដើម្បីជ្រោងអធិបតេយ្យនៃមាតុភូមិយើងឲ្យភ្លឺត្រចះ ដែលជាហេតុនាំឲ្យពុទ្ធសាសនា បានរុងរឿងដោយសារផង ៗ

អស់លោកអ្នកទាំងឡាយ ! ព្រះពុទ្ធសាសនានេះ ជាមតិកមួយដ៏ប្រសើរ ដែលដូនតាយើងចែកឲ្យមក ហើយមានទាំងពេលខ្លះ លោកបានលះជីវិត ដើម្បីរក្សាសាសនានេះទុកមកឲ្យយើងផង ៗ ដែលហៅថាមនុស្សល្អ គឺមនុស្សដែលចេះរក្សាមតិកនោះឲ្យបានគង់វង់ ៗ ដូច្នេះ

យើងមិនត្រូវបោះបង់ព្រះពុទ្ធសាសនា ដែលជាវិសក្ការៈរបស់ដូនតាយើងចោលឡើយ ។ ប៉ុន្តែបើយើងចង់ធ្វើឲ្យបានត្រឹមត្រូវ តាមតម្រាប់របស់បុព្វបុរសយើងនោះ យើងត្រូវតែនាំគ្នាខំផ្សាយសាសនានេះ ឲ្យរីកសុះសាយទៅក្នុងពិភពលោកទាំងមូល ។ ព្រោះព្រះធម៌របស់ព្រះពុទ្ធមិនមែនជារបស់អាថ៌កំបាំង សំរាប់លាក់មិនផ្សាយនោះទេ មិនមែនជារបស់សំរាប់តែប្រទេសណា ឬ ប្រជាជនណាម្នាក់ៗទេ គឺសំរាប់ពិភពលោកទាំងមូល ។

កាលព្រះសម្ពុទ្ធទ្រង់គង់ព្រះជន្មនៅឡើយ ទ្រង់បានត្រាស់បង្គាប់សាវ័កថា "ត្រូវនាំគ្នាខំផ្សាយដំបូន្មានរបស់តថាគតនេះ ក្នុងទីគ្រប់ទិសតាមដែលអាចធ្វើទៅបាន" ។

ក្នុងពុទ្ធប្រវត្តិ លើកដំបូងមានតែព្រះសង្ឃ ៥ អង្គ (បញ្ចវគ្គិយ) ទេ ដែលទទួលភារៈផ្សាយសាសនាផ្ទាល់ពីព្រះសម្មាសម្ពុទ្ធ ។ ព្រះសង្ឃ ៥ អង្គនេះ បាននិមន្តទៅបញ្ចុះបញ្ចូលបានសិស្សជាយ៉ាងច្រើន ដែលបានសាយពូជធាជរាបដល់សព្វថ្ងៃនេះ ដល់ទៅ ៣៥០ លាននាក់ ។ នេះគ្រាន់តែគណាចារ្យ ៥ រូបផង ។ ចុះប្រសិនបើ មានគណាចារ្យច្រើននាក់ទៀត ដែលប្រទេសកាន់ពុទ្ធសាសនាទាំងឡាយរួមកម្លាំងគ្នាបង្កើតឡើងនោះ ប្រជាជនក្នុងពិភពលោកទាំងមូល ដែលមានចំនួន ២.២៦៥ លាននាក់នោះ ក៏មុខជានឹងបានទទួលពន្លឺនៃពុទ្ធសាសនា

ទាំងអស់គ្នា ដោយឆាប់រួសរាន់ពុំខាន ។ ប៉ុន្តែខ្ញុំសូមរំលឹកថា ដើម្បីនឹងចាត់វិធានការនេះឲ្យសំរេចទៅបាន ត្រូវតែយើងខំរៀន, រៀនឲ្យព្រមៗគ្នា ហើយប្រែកម្មវិធីនៃការសិក្សារបស់យើងឲ្យទាន់សម័យឡើង ដើម្បីនឹងបង្កើតអាត្មានដែលប៉ុនប៉ាវ ទាំងខាងផ្លូវលោកទាំងខាងផ្លូវធម៌ អាចនឹងធ្វើបដិវាទជាមួយពួកបណ្ឌិតដែលមានវិជ្ជាជ្រៅជ្រះខាងផ្លូវលោក ក្នុងបច្ចុប្បន្ននេះបាន ។ គេមិនព្រមជឿយើងទេ បើកាលណាយើងមានចំណេះវិជ្ជាខ្សត់ខ្សោយជាងគេ ។ ការមិនជឿនេះ មិនអាចនឹងញុំាងសេចក្ដីសង្ស័យរបស់គេឲ្យអស់ទៅបាន ។ ត្រង់នេះហើយ ដែលខ្ញុំសូមក្រើនពុទ្ធបរិស័ទទាំងឡាយ ឲ្យឃើញច្បាស់នូវតំឡៃសមាគមពិភពលោក ដែលមានបំណងនឹងបង្កើតមជ្ឈមណ្ឌល នៃការសិក្សាពុទ្ធសាសនាឡើងវិញជាថ្មី នៅប្រទេសលង្កាតាមតម្រាយដែលធ្លាប់មានមក ហើយកាលពីសម័យបុរាណ សឹងមានមហាវិទ្យាល័យពុទ្ធសាសនាមួយ នៅមហាវិហារក្នុងអនុរាធបុរៈជាកស្តាង ។

អស់លោក-អ្នកជាបងប្អូនរួមសាសនាទាំងឡាយ? ក្នុងពេលដែលលោកសន្និវាស កំពុងតែត្រូវភ្លើងសង្គ្រាមឆេះយ៉ាងខ្លាំងនេះ មានអ្នកនយោបាយជាច្រើននាក់ បានបញ្ចេញយោបល់ផ្សេងៗគ្នា អំពីបំណងនឹងរំលត់ភ្លើងសង្គ្រាមនោះទៅវិញ ។ ខ្លះថាបើចង់ឲ្យបានសុខ ត្រូវធ្វើគ្រាប់បែកបរមាណូឲ្យបានច្រើន ខ្លះទៀតថា ត្រូវតែបង្កើតឲ្យមានពជការ

តែមួយនៅក្រោមមេឃនេះ ។ រឿងនេះមុខជាមិនបានសំរេចដូចបំណងទេ ព្រោះពៀរមិនអាចនឹងរម្ងាប់បានដោយការចងពៀរឡើយ ហើយដែលជាត្រូវតែដោះស្រាយ ដោយការបង្កើតកិច្ចការតែមួយ ក្នុងពិភពលោកនោះវិញ ក៏មិនងាយនឹងលត់ភ្លើងសង្គ្រាមឲ្យដាច់ស្រឡះក្នុងលោកទៅបានដែរ ព្រោះពួកគ្នាគេ មុខជាយកតែពួកគ្នាគេឲ្យធ្វើធំ ដែលនាំឲ្យមានសេចក្ដីមិនសុខចិត្តនឹងគ្នាកើតឡើងពុំខាន ។

ឯពួកយើងដែលជាអ្នកកាន់ពុទ្ធសាសនាវិញ គ្មានរឿងអ្វីទៅនិយាយនឹងគេទេ ព្រោះយើងមិនចេះធ្វើគ្រាប់បែកបរមាណូ ទាំងមិនចេះធ្វើកាំភ្លើង ។ ដូច្នេះហើយបានជាយើងត្រូវការនិយាយគ្នាតែពីរឿងពុទ្ធសាសនាដែលប្រដៅមិនឲ្យលោភលន់ មិនឲ្យបៀតបៀនគ្នា ទាំងមិនឲ្យប្រើអំណាចសក្ដិសក្ដិនបុគ្គលដទៃប៉ុណ្ណោះ ។ ក្នុងលោកនេះ យើងពួកពុទ្ធសាសនាមានគាតច្រើនជាងគេ ហើយគេមានជ័យជំនះមកលើយើងតែខាងផ្លូវអាវុធប៉ុណ្ណោះទេ; ចំណែកខាងផ្លូវសាសនាវិញ គ្មានអ្នកណាមួយនឹងអាចមកយកជ័យជំនះ លើកំឡាំងជំនឿរបស់យើងបានឡើយ គឺកម្លាំងទឹកចិត្តយើងនៅតែមានឥទ្ធិពលជានិច្ច ។ ដូច្នេះយើងមិនត្រូវគិតថា វត្ថុបំណងដែលយើងគិតនោះ ជាការហួសវិស័យនឹងសំរេចដូច្នេះទេ បើប្រសិនណាជាយើងខំប្រឹងប្រែងទាំងអស់គ្នា ។

ម្យ៉ាងទៀត ប្រទេសកម្ពុជានេះ មានពុទ្ធសាសនាប្រតិស្ឋាននៅដោយមុតមាំណាស់ ។ គោលចារិករបស់ពុទ្ធសាសនាគឺនគរវត្តដែល

រុងរឿងមាននាមល្បីស្ទុះសាយទៅក្នុងពិភពលោក ។ តាំងពីដើមមកគ្មានប្រទេសណាមួយ មានគ្រឿងសំគាល់សាសនាយ៉ាងធំដុំ ដូចប្រទេសកម្ពុជាទេ ។ ប្រទេសនេះបានផ្សាយពុទ្ធសាសនាទៅក្នុងកន្លែងនានា ស្ទើរតែគប់តំបន់ទាំងអស់ក្នុងសុវណ្ណភូមិ ដូចមានបុរាណវត្ថុនៃជាតិនេះ នៅជាភស្តុតាងដរាបដល់សព្វថ្ងៃ ។ ហេតុនេះ យើងដែលជាកូនចៅនៃអ្នកកាន់ពុទ្ធសាសនា ត្រូវតែយកតម្រាប់តាមដូនតាយើងមិនត្រូវបណ្តែតបណ្តោយឲ្យពេលវេលាដែលជាមាសប្រាក់រំលងយើងហួសទៅទៀតឡើយ ។

ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង បានទ្រង់ជាបង្អែកយ៉ាងមាំក្នុងការដែលបើកឲ្យប្រជារាស្ត្ររបស់ព្រះអង្គ ប្រតិបត្តិព្រះពុទ្ធសាសនានេះ ។ ឯកឧត្តម រដ្ឋមន្ត្រីក្រសួងធម្មការ ក៏បានជួយការពារយើងយ៉ាងពេញបន្ទុក ។ យើងមិនត្រូវខ្លាច មិនត្រូវរួញរាទេ ត្រូវតែហ៊ានបរិច្ចាគធនធាន ដើម្បីសេចក្តីរុងរឿងពុទ្ធសាសនា ដែលជាទីគោរពពន់ពេករបស់យើង ។

ចំពោះការផ្សាយសាសនានេះ ខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងមាំលើកិច្ចសិក្សានៃព្រះសង្ឃខ្មែរទាំងឡាយ ដែលមានសាលាបាលីជាន់ខ្ពស់ជាគោល ។ ប៉ុន្តែខ្ញុំសូមរំឭកថា ត្រូវតែខំសិក្សាបន្តទៅមុខទៀត ដើម្បីឲ្យចំណោះយើងបានជ្រៅជ្រះ ។

អស់លោក-អ្នកទាំងឡាយ! ខ្ញុំបានដើរច្រើនស្រុកណាស់ហើយ មិនធ្លាប់ឃើញប្រជាជនកន្លែងណា មានអធ្យាស្រ័យល្អដូចប្រជាជនខ្មែរនេះទេ ។

ថ្ងៃនេះជាថ្ងៃដែលពុទ្ធបរិស័ទខ្មែរធ្វើសក្ការបូជា, ដូច្នេះខ្ញុំសូមឲ្យអស់លោកទុកថ្ងៃនេះ ជាថ្ងៃចាប់ផ្ដើមជីវភាពថ្មីដែលយើងត្រូវតែរួបរួមគ្នា ដោយការឥតប្រកាន់ពួកគណៈ ។

មុននឹងបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណ យ៉ាងឧត្ដមចំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ចំពោះរដ្ឋាភិបាលដែលបានជួយឧបត្ថម្ភខ្ញុំ ឲ្យបានប្រកបដោយសេចក្ដីសុខស្រួលគ្រប់យ៉ាង; មិនតែប៉ុណ្ណោះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងស្មោះចំពោះ ដល់លោកអ្នកសប្បុរសទាំងឡាយ ដែលបានជូនកិត្តិយសដល់ខ្ញុំ ដោយប្រឹងទ្រាំនៅស្ដាប់បាឋកថាយ៉ាងវែងរបស់ខ្ញុំនេះដរាបដល់ចប់ ។ មួយទៀត ខ្ញុំមិនភ្លេចប្រាប់សេចក្ដីពាក់ទាក់របស់ប្រទេសកម្ពុជានេះ ដល់បងប្អូនខ្ញុំ ដល់មិត្តភក្តិខ្ញុំ ដល់រដ្ឋាភិបាលខ្ញុំទេ ។ ខ្ញុំសូមសន្យាថា បើលោក-អ្នកមានឱកាសនឹងអញ្ជើញទៅលេងលង្កាទ្វីប ដែលមានចង្កូមកែវជាបូជនីយស្ថាននោះ លោកអ្នកមុខជានឹងបានទទួលបដិសណ្ឋារៈយ៉ាងពាក់ទាក់ អំពីប្រជាជនលង្កាវិញពុំខាន ។

ចប់

---